# សង្គ្រាមស៊ីវិលនៅកម្ពុជា និងកិច្ចព្រមព្រៀងក្រុងប៉ារីស
## ក្នុងបរិបទសង្គ្រាមឥណ្ឌូចិនលើកទី៣( ពីឆ្នាំ១៩៧៩ ដល់ ឆ្នាំ១៩៩១ )

*បណ្ឌិត ជិន សុជាតិ មន្ត្រីស្រាវជ្រាវផ្នែកប្រវត្តិសាស្ត្រ*

*នៃវិទ្យាស្ថានសិក្សាចិន នៃរាជបណ្ឌិត្យសភាកម្ពុជា*

### ១.សង្គ្រាមឥណ្ឌូចិនទាំងបីលើក

*នៅក្នុងតំបន់ឥណ្ឌូចិននេះមានសង្គ្រាមចំនួនបីលើកធំៗ៖ សង្គ្រាមឥណ្ឌូចិនលើកទី១ (ពីឆ្នាំ១៩៤៦ ដល់ឆ្នាំ១៩៥៤) ជាសង្គ្រាមដណ្ដើមឯករាជ្យរបស់ប្រទេសទាំងបីដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់មហាអំណាចអាណានិគមបារាំង។ សង្គ្រាមនេះត្រូវបានបញ្ចប់ក្នុងក្របខ័ណ្ឌសន្និសីទអន្តរជាតិក្រុងសឺណែវ នាឆ្នាំ១៩៥៤។ ដោយឡែកសង្គ្រាមឥណ្ឌូចិនលើកទី២ (ពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៧៥) ជាសង្គ្រាមប្រឆាំងវត្តមានកងទ័ពសហរដ្ឋអាម៉េរិកក្នុងតំបន់ឥណ្ឌូចិនពីសំណាក់ប្រជាជនដែលមាននិន្នាការកុម្មុយនីស្ត និងនិន្នាអព្យាក្រិត្យនិយម។ សង្គ្រាមនេះបានបញ្ចប់ក្នុងកំឡុងពេលពួកកុម្មុយនីស្តបានចូលកាប់កាប់តំបន់ឥណ្ឌូចិន ដែលក្នុងនោះពួកខ្មែរក្រហមចូលកាន់កាប់ប្រទេសកម្ពុជា និងវៀតណាមកុម្មុយនីស្តចូលគ្រប់គ្រងវៀតណាមខាងត្បូង។*

*សង្គ្រាមឥណ្ឌូចិនលើកទី៣ (១៩៧៩ ដល់ ឆ្នាំ១៩៩១) ដែលភាពតានតឹងនេះគឺកើតឡើងពេលដែលកងទ័ពវៀតណាមចូលផ្ដួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ(ខ្មែរក្រហមនៅ*

កម្ពុជា) និងការវាយប្រហារដោយយោធារបស់ចិនទៅលើប្រទេសវៀតណាមនាដើមឆ្នាំ ១៩៧៩។ ការពិតចំណុចចាប់ផ្តើមសង្គ្រាមនេះវាបានចាប់ផ្តើមតាំងពីឆ្នាំ១៩៧៧ បង្កឡើងដោយជម្លោះរវាងរបបកម្ពុជាប្រជាធិបតេយ្យ និងប្រទេសវៀតណាម។ ការផ្លាស់ប្តូរភូមិសាស្ត្រនយោបាយសកលនាឆ្នាំ១៩៧៨ វារិតតែធ្វើឱ្យភាពតានតឹងកាន់តែកើនឡើង។ នៅឆ្នាំ១៩៧៨ ពេលដែលលោក តេង សៀវភីង បានចាប់ផ្តើមកំណែទម្រង់នយោបាយការទូត និងសេដ្ឋកិច្ចរបស់ខ្លួនឱ្យខិតជិតទៅសហរដ្ឋអាមេរិក ជាសញ្ញានៃការបែកបាក់គ្នារវាងមហាអំណាចកុម្មុយនីស្តពីរ គឺចិន និងសហភាពសូវៀត។ ប្រទេសវៀតណាមដែលធ្លាប់នៅក្រោមឥទ្ធិពលកុម្មុយនីស្តចិន ចាប់ផ្តើមមានទំនាក់ទំនងជិតស្និទជាមួយនឹងសហភាពសូវៀតនាឆ្នាំ១៩៧៨នេះផងដែរ ក្នុងគោលដៅទប់ការឈ្លានពានរបស់ចិន ឬក៏ប្រឆាំងរបបកម្ពុជាប្រជាធិបតេយ្យ(ដែលមានការគាំទ្រពីប្រទេសចិន)។

នៅខែធ្នូ ឆ្នាំ១៩៧៨ កងទ័ពវៀតណាមបានចាប់ផ្តើមចូលមកផ្តួលរំលំរបបខ្មែរក្រហមដោយសំអាងលើហេតុផលពីរ៖ ទី១ ឈរលើគោលការការណ៍ការពារខ្លួន ព្រោះខ្មែរក្រហមបានចូលឈ្លានពានវៀតណាម ទី២ ប្រជាជនកម្ពុជាមួយចំនួនដែលស្អប់អំពើប្រឆាំងមនុស្សជាតិរបស់ខ្មែរក្រហមបានស្នើឱ្យវៀតណាមជួយ ពីព្រោះមហាអំណាច និងអង្គការសហប្រជាជាតិគ្មានមធ្យោបាយណាមួយ ដើម្បីបញ្ឈប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរបស់ពួកខ្មែរក្រហមក្នុងប្រទេសកម្ពុជាបាន ។ របបខ្មែរក្រហមបានដួលរំលំនៅដើមខែមករា ឆ្នាំ១៩៧៩។

ការដួលរលំនៃរបបខ្មែរក្រហមធ្វើឱ្យប្រទេសចិនមានការព្រួយបារម្ភជាងគេ នឹងខិតខំស្វែងរកអន្តរាគមន៍នានាដើម្បីជួយពួកខ្មែរក្រហម។ អ្នកដែលព្រួយបារម្ភទី២ គឺថៃ ដែលជាសមាជិកដ៏សំខាន់របស់អាស៊ាន ។ ទំនាក់ទំនងចិន និងថៃចាប់ផ្តើមជាមួយគ្នាក្នុងការជួយទៅដល់ពួកខ្មែរក្រហមដើម្បីទប់ទល់ជាមួយកងទ័ពវៀតណាមដែលមានវត្តមាននៅកម្ពុជាជាងដប់ម៉ឺននាក់។ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៧៩ ចិនបានបញ្ជូនកងទ័ព ១៧០ ០០០ នាក់ដែល

មានយន្តហោះចម្បាំង ៧០០ គ្រឿង និងរថក្រោះ ២៥០-៣០០ លុកចូលក្នុងប្រទេសវៀតណាម ដើម្បីផ្តល់មេរៀនមួយឱ្យវៀតណាមពេលដែលទាត់ចោលចិន ចាប់យកទំនាក់ទំនងជាមួយសហភាពសូវៀត និងក៏ជាការដាក់ទណ្ឌកម្មក្នុងកំឡុងពេលទ័ពវៀតណាមមានវត្តមាននៅកម្ពុជា។ គឺផ្តើមពីការចូលឈ្លានពានរបស់ចិនលើទឹកដីវៀតណាមនេះហើយដែលពិភពលោកបានកំណត់ថា ជាកំណើតនៃសង្គ្រាមឥណ្ឌូចិនលើកទី៣។ មេរៀនទី១ដែលចិនបានផ្តល់ឱ្យវៀតណាមនេះមិនមែនជាភាពជោគជ័យរបស់ចិនទេ ប៉ុន្តែជាការបរាជ័យដ៏ធំមួយក្នុងពេលដែលសហភាពសូវៀតបានបញ្ជូនជំនួយយោធារបស់ខ្លួនទៅកាន់វៀតណាមដើម្បីវាយបកលើកងទ័ពចិន។ មិនត្រឹមតែប៉ុណ្ណោះ សហភាពសូវៀតបានជួយគាំទ្រផ្នែកយោធាលើកងទ័ពវៀតណាមដែលឈរជើងនៅកម្ពុជាផងដែរ ។ បញ្ហាតានតឹងនេះបានបន្តរហូតដល់ឆ្នាំ១៩៩១ វាត្រូវបានបញ្ចប់នៅពេលប្រទេសចិន និងសហភាពសូវៀត ប្រទេសចិន និងប្រទេសវៀតណាមភ្ជាប់ចំណងការទូតជាមួយគ្នាឡើងវិញ ហើយក៏ត្រូវបានគេមើលឃើញថា កិច្ចព្រមព្រៀងក្រុងប៉ារីស៍ ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ គឺជាការបិតបញ្ចប់ទាំងស្រុងនៃសង្គ្រាមឥណ្ឌូចិនលើកទី៣នេះ។

## ២.ជម្លោះផ្ទៃក្នុងប្រទេសកម្ពុជា និងបញ្ហាអន្តរជាតិ

នៅក្នុងដំណាក់កាលសង្គ្រាមឥណ្ឌូចិនលើកទី៣(ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩១នេះ) សង្គ្រាមស៊ីវិលបានបន្តកើតមានដោយដំបូងឡើយជម្លោះកើតមានរវាងក្រុមសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលអ្នកប្រវត្តិសាស្ត្រមួយចំនួនហៅក្រុមនេះថា រដ្ឋាភិបាលក្រុងភ្នំពេញ (មានការគាំទ្រពីកងទ័ពវៀតណាម និងការគាំទ្រយោធា និងសេដ្ឋកិច្ចពីសហភាពសូវៀត) និងក្រុមខ្មែរក្រហមដែលគាំទ្រដោយប្រទេសចិន និងប្រទេសថៃ។

ទាំងប្រទេសចិន ទាំងបណ្តាប្រទេសសមាជិកអាស៊ាន ទាំងប្រទេសលោកសេរី រួមទាំងអង្គការសហប្រជាជាតិគឺសុទ្ធតែបានចេញសេចក្តីថ្លែងការនានា ដើម្បីឱ្យកងទ័ពវៀត

ណាមដកចេញពីកម្ពុជា និងថែមទាំងបានបន្តទទួលស្គាល់របបកម្ពុជាប្រជាធិបតេយ្យ(ខ្មែរក្រហម) ជារដ្ឋាភិបាលស្របច្បាប់នៅអង្គការសហប្រជាជាតិដដែល។ ទោះបីរដ្ឋាភិបាលក្រុងភ្នំពេញមានចំណុចខ្សោយលើនយោបាយការទូតដើម្បីគៀរគរប្រទេសផ្សេងៗគាំទ្ររបបគ្រប់គ្រងរបស់ខ្លួននៅកម្ពុជា ប៉ុន្តែចំណុចខ្លាំងរបស់ក្រុមនេះគឺបានគ្រប់គ្រងផ្ទៃដីប្រទេសកម្ពុជាជាង ៨០ ភាគរយ ។ នៅក្នុងកំឡុងពាក់កណ្តាលខែមករា ឆ្នាំ១៩៧៩ សហភាពសូវៀត និងឆេកូស្លូវ៉ាគីបានប្រឆាំងនឹងសេចក្តីសម្រេចមួយ របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដែលអំពាវនាវឱ្យដក "កងកម្លាំងបរទេសទាំងអស់" ពីកម្ពុជា ហើយថា ការដកកងទ័ពវៀតណាមនឹងធ្វើឱ្យរបបខ្មែរក្រហមវិលត្រឡប់មកកាន់អំណាចវិញ។ រឿងដែលពិបាកដោះស្រាយត្រង់ថា ខ្មែរក្រហមគឺជាក្រុមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ហេតុនេះភាពជាប់គាំងនៃជម្លោះបានបន្ត និងគ្មានដំណោះស្រាយ។

នៅខែតុលា ឆ្នាំ១៩៧៩ ក្រុមអ្នកតស៊ូខ្មែរថ្មីមួយក្រុមដែលមាននិន្នាការសេរីនិយមបានបង្កើតឡើង នៅជំរំសុខសាន្ត គឺ «រណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរ» (Front nationde libération du peuple Khmer /FNKPK) ក្រោមការដឹកនាំរបស់លោក សឺន សាន ដែលមានកម្លាំងប្រដាប់អាវុធប្រមាណ ២០០០នាក់ ។ បន្ទាប់មកនៅខែវិច្ឆិកា ព្រឹទ្ធសភាអាម៉េរិកបានអនុម័តសេចក្តីសម្រេចដើម្បីធ្វើការជាមួយអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ និងជាមួយប្រជាជាតិដទៃទៀត ដើម្បីរៀបចំសន្និសីទអន្តរជាតិស្តីពីកម្ពុជា។ ចំណែក សម្តេចនរោត្តម សីហនុ បានរៀបចំគម្រោងបង្កើត ចលនារណសិរ្សបង្រួបបង្រួមជាតិកម្ពុជាមួយ ដើម្បី អព្យាក្រិត សន្តិភាព និងសហប្រតិបត្តិការ (Front uni national pour un cambodge neuth pacifique et coopératif ហៅកាត់ថា Funcinpec (ហ្វុនស៊ីនប៉ិច) នៅថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៨១។

បណ្ដាប្រទេសអាស៊ាន ចិន និងសហរដ្ឋអាម៉េរិកបានបន្តគាំទ្រដល់ចលនាតស៊ូត្រីភាគី ដើម្បីប្រឆាំងវត្តមានកងទ័ពវៀតណាមនៅកម្ពុជា។ ប្រទេសវៀតណាម ក៏ដូចជាសហភាពសូវៀតលើកឡើងថា ការដកកងទ័ពវៀតណាមគឺត្រូវគិតពីការវិលត្រឡប់មកកាន់អំណាចឡើងវិញរបស់ពួកខ្មែរក្រហម។ នៅក្នុងសន្និសីទរដ្ឋមន្ត្រីការបរទេសឥណ្ឌូចិនប្រចាំឆ្នាំលើកទី៥ បានប្រារព្ធធ្វើនៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ នាថ្ងៃទី ១៦-១៨ ខែកុម្ភៈ ឆ្នាំ១៩៨២ លើកឡើងថាថា កងទ័ពវៀតណាមទាំងអស់ នឹងចាកចេញពីកម្ពុជា "នៅពេលដែល ការគំរាមកំហែងនៃការពង្រីកអនុត្តរភាពនិយមរបស់ចិន ត្រូវបានដកចេញ"។ សេចក្ដីថ្លែងការនេះបង្ហាញថា បញ្ហាកម្ពុជា មិនមែនជាបញ្ហាជម្លោះផ្ទៃក្នុងទេ តែគឺជាបញ្ហាអន្តរជាតិ ហើយអង្គការសហប្រជាជាតិជាអ្នកដើរតួនាទីសំខាន់ក្នុងការដោះស្រាយ។

ភាពជាប់គាំងនៃដំណោះស្រាយបាននាំទៅដល់ការបង្កើតសម្ព័ន្ធភាពថ្មីរវាងចលនាតស៊ូត្រីភាគីនៅជាយដែន ពោលគឺនៅក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី នាខែមិថុនាមានសេចក្ដីប្រកាសបង្កើតរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ(CGDK) បានកើតឡើងដោយមានមេដឹកនាំ៣ រូបមានសម្ដេចនរោត្តម សីហនុ, ខៀវ សំផន និងសឺន សាន។ រដ្ឋាភិបាលចម្រុះនេះមានការជួយឧបត្ថម្ភពីក្រុងវ៉ាស៊ីនតោន។ គោលបំណងនៃរដ្ឋាភិបាលចម្រុះនេះ មានពីរយ៉ាងគឺ (1) ប្រមូលផ្ដុំកិច្ចខិតខំប្រឹងប្រែងទាំងអស់ក្នុងការតស៊ូរួមដើម្បីរំដោះកម្ពុជាចេញពីការគ្រប់គ្រងវៀតណាម បង្កើតឱ្យមានមាតុភូមិជាប្រទេសអធិបតេយ្យ និងឯករាជ្យ។ និង (2) ដើម្បីនាំមកនូវការអនុវត្តន៍សេចក្ដីប្រកាសនៃសន្និសីទអន្តរជាតិស្ដីពីកម្ពុជា និងដំណោះស្រាយនៃអង្គការសហ ប្រជាជាតិដែលពាក់ព័ន្ធដទៃទៀត។

ការបង្កើតរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ(CGDK) បាននាំឱ្យជម្លោះកាន់តែកើនកំដៅ ជាពិសេសនៅក្នុងរដូវកាល ឆ្នាំ១៩៨៤ និង១៩៨៥ កងទ័ពវៀតណាមបង្កើនការវាយប្រហារទៅលើក្រុមអ្នកតស៊ូទាំងបីក្រុមកាន់តែច្រើនថែមទៀត ដែលជាហេតុធ្វើឱ្យ

ប្រទេសថៃ និងចិនមានការព្រួយបារម្ភកាន់តែខ្លាំងឡើង និងបានស្វែងរកការដាក់សម្ពាធលើប្រទេសវៀតណាមថែមទៀត ជាពិសេសប្រទេសចិនបានគំរាមថានឹងផ្តល់មេរៀនលើកទី២ (បញ្ជូនយោធាទៅកាន់វៀតណាមជាលើកទី២)ទៅលើប្រទេសវៀតណាម។

នៅខែកុម្ភៈ ឆ្នាំ១៩៨៥ សម្តេចនរោត្តម សីហនុ ដែលទ្រង់គង់នៅក្នុងប្រទេសអូស្ត្រាលី បន្តស្នើសុំឱ្យមានសន្និសីទអន្តរជាតិស្តីពីកម្ពុជា ក្នុងខែបន្ទាប់មក វៀតណាមបានឯកភាពឱ្យមានសន្និសីទអន្តរជាតិស្តីពីកម្ពុជា ដែលបានស្នើដោយសម្តេចនរោត្តម សីហនុ កាលពីខែមុននោះ នៅលើលក្ខខណ្ឌដែលព្រះអង្គត្រូវដកខ្លួនចេញពីពួកខ្មែរក្រហម ។ ពេលនោះ លោក ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរដ្ឋាភិបាលក្រុងភ្នំពេញ បានបង្ហាញពីតម្រូវការប្រាំមួយសម្រាប់ដោះស្រាយបញ្ហាកម្ពុជា: (1) ការលុបបំបាត់កងកម្លាំង ប៉ុល ពត ទាំងខាងនយោបាយនិងយោធា។ (2) ការដកកងទ័ពវៀតណាមបន្ទាប់ពី ប៉ុល ពត ត្រូវបានលុបបំបាត់។ (3) ការបោះឆ្នោតដោយសេរី និងដែលអាចត្រួតពិនិត្យបានអាចត្រូវបានធ្វើឡើងភ្លាមៗ ប្រសិនបើបុគ្គល និងក្រុមមួយចំនួនចូលរួមជាមួយ សាធារណៈរដ្ឋប្រជាមានិតកម្ពុជាប្រឆាំងនឹងក្រុមប៉ុលពត។ (4) ការបង្កើតភាពសុខដុមរមនា និងស្ថេរភាពដោយសន្តិវិធីក្នុងចំណោមបណ្តាប្រទេសអាស៊ីអាគ្នេយ៍ដែលមានរបបនយោបាយនិងសង្គមខុសៗគ្នា។ (5) ការបញ្ឈប់ការជ្រៀតជ្រែកពីសំណាក់ប្រទេសក្រៅតំបន់។ និង (6) ការបង្កើតការធានាអន្តរជាតិ និងការត្រួតពិនិត្យកិច្ចព្រមព្រៀងខាងលើ។

នៅខែកក្កដា ឆ្នាំ១៩៨៥ អាស៊ាន បានចេញសេចក្តីថ្លែងការណ៍រួមមួយអះអាងជាថ្មីនូវជំហរ ៤ ចំណុចរបស់ខ្លួនក្នុងការដោះស្រាយបញ្ហាកម្ពុជា ៖ (1) ការដកកងកម្លាំងបរទេសពីកម្ពុជា; (2)បង្កើតគណៈកម្មាធិការត្រួតពិនិត្យ និងគ្រប់គ្រងនៃអង្គការសហប្រជាជាតិ (3) មូលដ្ឋានផ្សះផ្សាជាតិកំណត់ដោយខ្លួនឯង និង (4) ការបោះឆ្នោតដែលត្រូវបានត្រួតពិនិត្យ។ ចំណែកឯ លោករដ្ឋមន្ត្រីការបរទេសជប៉ុន ស៊ីតារ៉ូ អាបេ បានប្រកាសពីផែនការសន្តិភាព ៣

ចំណុចរបស់ប្រទេសកម្ពុជាសម្រាប់ប្រទេសកម្ពុជាៈ ទី១ ជប៉ុននឹងគាំទ្រកងកម្លាំងរក្សាសន្តិភាពនៅក្នុងតំបន់នេះ បន្ទាប់ពីការដកចេញជាដំណាក់កាលរបស់វៀតណាម។ ទី២ ប្រជាជាតិប្រជាធិបតេយ្យនឹងបញ្ជូនបុគ្គលិកដើម្បីត្រួតពិនិត្យការបោះឆ្នោតកម្ពុជា។ ទី៣ ជប៉ុននឹងផ្តល់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងជំនួយបច្ចេកទេសសម្រាប់ការ កសាងឡើងវិញនៅក្នុងបណ្តាប្រទេសឥណ្ឌូចិន។

រីឯក្រុមរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ នាខែមីនា ឆ្នាំ១៩៨៦ បានស្នើសុំផែនការ៨ ចំណុចៈ១.វៀតណាមដកកងទ័ពចេញពីកម្ពុជាក្រោយពីការចរចារវាងរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ និង វៀតណាម។ ២.ឈប់បាញ់គ្នាក្នុងរយៈពេលកំពុងដកទ័ពវៀតណាម។ ៣.អ្នកសង្កេតការណ៍អង្គការសហប្រជាជាតិត្រួតពិនិត្យការដកកងទ័ពវៀតណាម។ ៤.រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យនិងរដ្ឋាភិបាលសាធារណៈរដ្ឋប្រជាមានិតកម្ពុជារួមគ្នាចាត់រដ្ឋាភិបាលចម្រុះមួយដែលមាន សម្តេចនរោត្តម សីហនុ ជាប្រធាន និងលោក សឺន សាន ជានាយករដ្ឋមន្ត្រី។ ៥.បោះឆ្នោតដោយសេរី ក្រោមការត្រួតពិនិត្យរបស់អង្គការសហប្រជាជាតិ។ ៦.អង្គការសហប្រជាជាតិធានាអធិបតេយ្យភាព និង អព្យាក្រឹតភាពកម្ពុជាក្នុងរយៈពេល២ទៅ៣ឆ្នាំ។ ៧.ទទួលជំនួយពីគ្រប់ប្រទេសទាំង អស់ដើម្បីកសាងកម្ពុជាឡើងវិញ។ ៨.កម្ពុជានិងវៀតណាមចុះសន្ធិ សញ្ញាមិនឈ្លានពានគ្នានិងរួមរស់ជាមួយគ្នាដោយសន្តិភាព។ ប្រទេសចិនបានប្រកាសគាំទ្រផែនការ៨ខនេះភ្លាមៗ ខណៈពេលដែលវៀតណាមបានបដិសេធ។ ផែនការ៨ចំណុចរបស់ រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យក្រោយមកមានការគាំទ្រពីសមាជិកប្រទេសអាស៊ាន និងសហភាពអឺរ៉ុប។

នៅខែកញ្ញា ឆ្នាំ១៩៨៦ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានផ្ញើសារទៅអង្គការសហប្រជាជាតិថា សំណើរបស់រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យអាចនឹងយកមកពិចារណា បើសិនមានការជំនុំជម្រះជាអន្តរជាតិ លើអ្នកនយោបាយ (ដែលពាក់ព័ន្ធអំពើ

ប្រល័យពូជសាសន៍) ក្នុងរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ និងការដកចេញនូវគណៈប្រតិភូរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យពីអង្គការសហប្រជាជាតិ។

ចាប់ពីចុងឆ្នាំ១៩៨៦ ភាពតានតឹងនៃជម្លោះមហាអំណាចក្នុងសង្គ្រាមត្រជាក់ត្រូវបានធ្លាក់ចុះ ដោយគេសង្កេតឃើញថា សហភាពសូវៀតចាប់ផ្តើមចរចាជាមួយចិនអំពីបញ្ហាកម្ពុជា ហើយវៀតណាមបន្ទាប់ពីចាប់ផ្តើមឱ្យអនុវត្តនូវនយោបាយ "ដូម៉ូយ" (Doi Moi) បានចាប់ផ្តើមទាក់ទងនឹងសម្តេចនរោត្តម សីហនុ ដើម្បីស្វែករកដំណោះស្រាយកម្ពុជា ។ វៀតណាមលើកឡើងថា នឹងដកកងទ័ពរបស់ខ្លួនឱ្យអស់ពីកម្ពុជា ទន្ទឹមគ្នានឹងការទាត់ចោលទាំងកម្លាំងនយោបាយ និងយោធានៃក្រុមពួក ប៉ុល ពត ។

នៅខែមករា ឆ្នាំ១៩៨៧ លោក ហ៊ុន សែន តំណាងរដ្ឋាភិបាលក្រុងភ្នំពេញ ប្រកាសថា លោករង់ចាំជានិច្ច ដើម្បីជួបសម្តេចនរោត្តម សីហនុ ហើយសម្តេចនរោត្តម សីហនុ ក៏បានយល់ព្រមធ្វើការចរចាឡើងវិញដែរ ។ នៅថ្ងៃទី៨ ខែតុលា ឆ្នាំ១៩៨៧ សាធារណៈរដ្ឋប្រជាមានិតកម្ពុជា ផ្សាយសេចក្តីថ្លែងការណ៍៥ខដើម្បីដោះស្រាយបញ្ហាកម្ពុជា ៖

១.ជួបចរចាសាធារណៈរដ្ឋប្រជាមានិតកម្ពុជា និងសម្តេចនរោត្តម សីហនុ។

២.ដកកងទ័ពវៀតណាមទាំងអស់ ព្រមជាមួយគ្នានឹងការឈប់ផ្តល់ជំនួយ និងជម្រកទាំងអស់ដល់កម្លាំងរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ។

៣.បោះឆ្នោតទូទៅ ក្រោមការត្រួតពិនិត្យរបស់អ្នកសង្កេតការណ៍បរទេស ដើម្បីចាត់តាំងរដ្ឋាភិបាលមួយ ដែលអនុវត្តនយោបាយ អព្យាក្រឹត និង មិនចូលបក្សសម្ព័ន្ធ។

៤.ចរចាជាមួយថៃ ដើម្បីកសាងព្រំដែនមួយច្បាស់លាស់ និង ប្រកបដោយសន្តិភាព ហើយរៀបចំដឹកជញ្ជូនជនភៀសខ្លួនដែលស្ម័គ្រចិត្តត្រឡប់មកក្នុងប្រទេសវិញ។

៥.ប្រជុំសន្និសីទអន្តរជាតិមួយ ដើម្បីធានាកិច្ចព្រមព្រៀងខាងលើនេះដោយមានការចូលរួមពីរដ្ឋាភិបាលកម្ពុជាទាំងពីរ ពីសមាជិកអចិន្ត្រៃយ៍ទាំង៥នៃក្រុមប្រឹក្សាសន្តិសុខ ពីវៀតណាម ឥណ្ឌា និង ប្រទេសមួយចំនួនទៀត។

នៅថ្ងៃទី២-៤ ខែធ្នូ ឆ្នាំ១៩៨៧ សម្តេចនរោត្តម សីហនុ ជួបចរចាលើកទី១ រវាងសីហនុ-ហ៊ុន សែននៅ ហ្វែអង់តាដឺណ័រ ជិតទីក្រុងប៉ារីសរយៈពេល៣ថ្ងៃ និងមានសេចក្តីប្រកាសរួម៤ខ ៖

១.បញ្ហាកម្ពុជាត្រូវដោះស្រាយតាមនយោបាយ មិនតាមយោធាទេ។

២.បញ្ហាកម្ពុជាត្រូវដោះស្រាយរវាងកម្ពុជាគ្នាឯង តាមការចរចា។

៣.ត្រូវស្វែងរកសន្តិភាព ការកសាងប្រទេសឡើងវិញ និង ការបង្កើតរបបនយោបាយមួយឯករាជ្យ ប្រជាធិបតេយ្យ អធិបតេយ្យ អព្យាក្រឹត និង មិនចូលបក្សសម្ព័ន្ធ។

៤.ជំនួបលើកក្រោយនឹងត្រូវប្រព្រឹត្តទៅនៅខែមករា ឆ្នាំ១៩៨៨។

នៅថ្ងៃទី២០-២១ ខែមករា ឆ្នាំ១៩៨៨ សម្តេចនរោត្តម សីហនុ និងលោក ហ៊ុន សែន បានជួបពិភាក្សាជុំទីពីរ នៅ Saint Germain-en-Laye ប្រទេសបារាំង ។ វាជាលើកដំបូង ដែលសាធារណៈរដ្ឋប្រជាមានិតកម្ពុជា មានឆន្ទៈក្នុងការដោះស្រាយជាមួយពួកមេដឹកនាំខ្មែរក្រហម ខៀវ សំផនតែមិនមែនក្រុម ប៉ុល ពត ទេ។ នៅខែកុម្ភៈ ឆ្នាំ១៩៨៨ ប៉ុល ពត បានចេញការណែនាំថ្មី១ទៀតដែលបន្ថែមពីផែនការកំចាត់២ កសាង៣ ទៅជាផែនការកំចាត់២កសាង៤។ កំចាត់ពីរគឺកំចាត់កងកម្លាំងមូលដ្ឋាន និងអាជ្ញាធរមូលដ្ឋានរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា និងកសាង៤ គឺ កសាងក្រុមស្នូលតាមគ្រួសារនៅមូលដ្ឋាន កសាងកម្លាំងបង្កប់ ក្នុងគ្រួសារស្នូល កសាងកងឈ្លបក្នុងគ្រួសារ និងតាមភូមិនានា។ ទង្វើនេះត្រូវបានគេមើលឃើញថា ជាការឆ្លើយតបទៅភាគីក្រុងភ្នំពេញដែលទាត់ចោលក្រុម ប៉ុល ពត។

ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៨៨ ការជួបប្រជុំរវាងភាគីខ្មែរទាំង៤ ជាមួយបណ្តាមេដឹកនាំប្រទេសមិនចូលបក្សសម្ព័ន្ធនៅញូវដេលី ប្រទេសឥណ្ឌា ដើម្បីពិគ្រោះយោបល់ពីបញ្ហាកម្ពុជា កិច្ចប្រជុំនេះក៏បានបន្តធ្វើនៅឥណ្ឌូណេស៊ី។ ថ្ងៃទី២០ ដល់ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៨៨ កិច្ចប្រជុំក្រៅផ្លូវការលើកទី១រវាងភាគីកម្ពុជាទាំងអស់នៅ ក្រុងហ្សាកាតា ឥណ្ឌូណេស៊ី គេហៅអង្គប្រជុំនេះថាហ្ស៊ីម (JIM I= First Jakarta Informal Meeting)ភាគីនីមួយៗបានបង្ហាញពីជំហររៀងៗខ្លួន។ នេះជាលើកទី១ ដែលភាគីទាំងបួនបានជួបប្រជុំទល់មុខគ្នា និងក៏មានជំនួបទ្វេភាគីនានាក្នុងចំណោមភាគីទាំង៤ផងដែរ។ នៅហ្សាការតាប្រទេសឥណ្ឌូណេស៊ី សម្តេចនរោត្តម សីហនុ បានថ្លែងចំពោះអ្នកពត៌មាន អំពីលទ្ធភាពនៃការធ្វើសម្ព័ន្ធភាពរវាងក្រុមគាត់ជាមួយរដ្ឋាភិបាលក្រុងភ្នំពេញ ដើម្បីទប់ស្កាត់ពួកខ្មែរក្រហម ព្រោះពួកនេះបានវាយលើកងទ័ពព្រះអង្គ។ លោក សឺន សានមិនពេញចិត្តនឹងសំណើនេះទេ ជាហេតុធ្វើឱ្យសម្តេចនរោត្តម សីហនុ បានលាលែងពីក្រុមរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ខណៈពេលដែលលោក ហ៊ុន សែន ស្នើឱ្យអសនៈកម្ពុជានៅអង្គការសហប្រជាជាតិព្យួរទុកឱ្យនៅទំនេរបណ្តោះអាសន្ន។ រីឯពួកខ្មែរក្រហមវិញបានដាក់ចេញនូវសំណើ១៤ ចំណុចដែលក្នុងនោះ មានចំណុចមួយចំនួននិយាយថា «ផ្សះផ្សាជាតិរវាងជនជាតិកម្ពុជាទាំងអស់ និងគណៈបក្សទាំងអស់ដោយមិនគិតគូរដល់អតីតកាល និងនិន្នាការនយោបាយរបស់អ្នកណាទាំងអស់»។ ចំនុចមួយទៀតដែលគួរឱ្យចាប់អារម្មណ៍នោះគឺសំណើការចែកអំណាចស្មើគ្នាទាំងនយោបាយ និងយោធាដោយមានការត្រួតពិនិត្យអន្តរជាតិ។ ប៉ុន្តែសំណើនេះមិនត្រូវបានគេយកចិត្តទុកដាក់ឡើយ។

នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៨៨ ប្រទេសវៀតណាម បានជំទាស់ទៅនឹងការស្នើសុំរបស់អង្គការសហប្រជាជាតិ ដែលស្នើឱ្យវៀតណាមបង្ហាញភាពច្បាស់លាស់នៃការដកកងទ័ពរបស់ខ្លួនចេញពីកម្ពុជា និងមានការត្រួតពិនិត្យពីអន្តរជាតិ ដោយលើកឡើងថា អង្គការ

សហប្រជាជាតិមិនទាន់មានវិធានការជាក់លាក់ ក្នុងការទប់ស្កាត់នៃរបបខ្មែរក្រហមនៅឡើយទេ។

នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៨៨ នៅអង្គការសហប្រជាជាតិ មានការបោះឆ្នោតសម្រេចចិត្តមួយដែលមិនអនុញ្ញាតឱ្យក្រុមអ្នកស្មោះត្រង់នឹងប៉ុលពត ឡើងកាន់អំណាចក្នុងប្រទេសកម្ពុជាឡើងវិញឡើយ។ ការសម្រេចចិត្តនេះដើម្បីឆ្លើយតបទៅនឹងវៀតណាមដែលថា ខ្លួននឹងដកកងទ័ពចេញពីកម្ពុជា ប្រសិនបើមានវិធានការជាក់លាក់ ក្នុងការទប់ស្កាត់ពួកខ្មែរក្រហមមកកាន់អំណាចនៅកម្ពុជាវិញ និងក៏ទាមទារឱ្យមានការរំលាយរដ្ឋាភិបាលនានាដោយបង្កើតរដ្ឋាភិបាលបណ្តោះអាសន្នមួយ។

នៅខែធ្នូ ឆ្នាំ១៩៨៨មានកិច្ចប្រជុំគណៈកម្មការការងារស្តីពីកម្ពុជា តាមគម្រោងរបាយការណ៍កិច្ចប្រជុំនេះ នឹងលើកឡើងអំពីផែនការសន្តិភាព៥ប្រការដែលស្នើឡើងដោយសម្តេចនរោត្តម សីហនុ។ ក្នុងចំណោមផែនការសន្តិភាព មានផែនការបីសំខាន់គឺ ទី១កាលបរិច្ឆេទការដកកងទ័ពវៀតណាមចេញពីកម្ពុជា ទី២លុបបំបាត់ព្រមគ្នានូវរដ្ឋាភិបាលក្រុងភ្នំពេញ និងរដ្ឋាភិបាលចម្រុះត្រីភាគី ទី៣ ការរៀបចំការបោះឆ្នោតជាទូទៅមួយដើម្បីឱ្យប្រជាជនកម្ពុជាជ្រើសរើសអ្នកដឹកនាំថ្មីសម្រាប់ប្រទេសកម្ពុជា។ កិច្ចប្រជុំនេះក៏នៅតែមានការខ្វែងគំនិតគ្នា គឺទាក់ទងនឹងការដកកងទ័ពវៀតណាម ដែលភាគីក្រុងភ្នំពេញលើកឡើងថា ទីប្រឹក្សាវៀតណាម និងកងទ័ពវៀតណាមបានដកចេញពីកម្ពុជារួចស្រេចទៅហើយ និងមួយទៀតភាគីក្រុងភ្នំពេញបានលើកឡើងថា ទាល់តែមានការបញ្ឈប់ជំនួយអន្តរជាតិទៅឱ្យពួកខ្មែរក្រហមសិន។

ថ្ងៃទី ១៩-២១ ខែកុម្ភៈ ឆ្នាំ១៩៨៩ កិច្ចប្រជុំក្រៅផ្លូវការនៅហ្សាកាតា (Jakarata informal meeting)លើកទី២ ស្តីពីបញ្ហាកម្ពុជាត្រូវបានចាប់ផ្តើមជាថ្មីទៀត។ កិច្ចប្រជុំនេះមិនទាន់បានស្រុះស្រួលគ្នាលើកការរៀបចំសមាសភាពរដ្ឋាភិបាលបណ្តោះអាសន្នដែលមាន ៤

ភាគីនោះទេ។ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៨៩ កិច្ចប្រជុំជាលើកទី៣របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិនៅ"បារីស" ដែលបានស្នើឱ្យមានក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជាមួយដែលនឹងត្រូវទទួលអសនៈកម្ពុជានៅអង្គការសហប្រជាជាតិ"។ ឯសមាសភាពក្រុមប្រឹក្សាជាន់ខ្ពស់ (SNC) ត្រូវមានការយល់ព្រមកំណត់ពីភាគីទាំង៤។

ថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៨៩ វៀតណាមជូនដំណឹងថា នឹងដកកងទ័ពចេញពីប្រទេសកម្ពុជា នៅដំណាច់ខែកញ្ញា ឆ្នាំ១៩៨៩ ស្របពេលដែលរដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានផ្តល់សច្ចាប័នលើរដ្ឋ ធម្មនុញ្ញធ្វើវិសោធនកម្ម ប្រទេសត្រូវបានប្តូរឈ្មោះពីសាធារណរដ្ឋ ប្រជាមានិតកម្ពុជាទៅជា រដ្ឋកម្ពុជា (SOC)។ ភ្លេងជាតិថ្មី និងទង់ជាតិថ្មីត្រូវបានអនុម័ត។ ទោសប្រហារជីវិតត្រូវបានលុបចោល ហើយប្រកាសយកព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ មានកម្មសិទ្ធិឯកជន និងមានសេដ្ឋកិច្ចទីផ្សារសេរី លុបចោលពាក្យសង្គមនិយមពីរដ្ឋធម្មនុញ្ញកម្ពុជា ហើយជំនួសថាពាក្យអព្យាក្រឹត្យមិនចូលបក្សសម្ព័ន្ធដែល បានអនុម័តដោយរដ្ឋសភា និងប្រថាប់ត្រាដោយលោក ហេង សំរិន។

នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៨៩ នៅក្នុងអង្គប្រជុំកំពូលមួយនៅទីក្រុងប៉េកាំង រវាងចិន និងសហភាពសូវៀត គូភាគីទាំងសងខាងបានយល់ព្រមគ្នា កាត់បន្ថយជំនួយទៅឲ្យក្រុមខ្មែរទាំងអស់នៅក្នុងស្រុក ដើម្បីចៀសវាងកុំឲ្យមានសង្គ្រាមផ្ទៃក្នុងនៅកម្ពុជា ហើយដើម្បីសម្រួលដល់ការការចរចាគ្នារវាងខ្មែរ និងខ្មែរ។ គូភាគីក៏បានលើកឡើងអំពី ការសម្រេចចិត្តលើការដកកងទ័ពវៀតណាមចេញពីប្រទេសកម្ពុជាដែលនឹងធ្វើឡើងនៅខែកញ្ញា និងបញ្ហានៃការផ្លាស់ប្តូរនយោបាយរបស់ក្រុងភ្នំពេញផងដែរ។ នៅក្នុងទីក្រុងប៉េកាំងភាគីចិនបានទាមទារឲ្យបង្កើតនៅក្នុងដំណាក់កាលនូវរដ្ឋាភិបាលចំម្រុះចតុភាគីបណ្តោះអាសន្នក្រោមការដឹកនាំរបស់សម្តេចនរោត្តម សីហនុ។ ស្របពេលនេះដែរ វៀតណាមបានរៀបចំដកកងទ័ពរបស់ខ្លួនលើកចុងក្រោយពីកម្ពុជា។ ចំណែក សម្តេចនរោត្តម សីហនុ លើកឡើង

នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ ១៩៨៩ថា បើទុកឱ្យក្រុមខ្មែរក្រហមនៅក្រៅច្បាប់គឺជារឿងគ្រោះថ្នាក់ ។ ព្រះអង្គទាមទារឱ្យមានការត្រួតពិនិត្យ នៃការដកកងទ័ពវៀតណាមស្ថិតក្រោមការត្រួតពិនិត្យពីអង្គការសហប្រជាជាតិ ។ ព្រះអង្គប្រកាសមិនទទួលស្គាល់រដ្ឋបាល និងរដ្ឋធម្មនុញ្ញរបស់រដ្ឋកម្ពុជាផងដែរ។

ជំនួបរវាងសម្តេចនរោត្តម សីហនុ និង លោក ហ៊ុន សែន នាថ្ងៃទី២៥ ខែកក្កដា ឆ្នាំ ១៩៨៩ នៅ "ឡាសែលសាំងក្លូរ"(La celle saint Cloud)ប្រទេសបារាំង ។ សម្តេចនរោត្តមសីហនុ ស្នើឱ្យមានរដ្ឋាភិបាលពហុបក្សមកពីភាគីទាំងបួនក្រុម តែលោក ហ៊ុន សែន ជំទាស់ ជាពិសេសលើពួកខ្មែរក្រហម។ យ៉ាងណា ជំនួបនេះមានដំណើរទៅរកការព្រមព្រៀងគ្នាលើការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ជាតិនៃកម្ពុជាមួយដែលតំណាងឱ្យភាពស្របច្បាប់របស់បណ្តោះអាសន្ន នៅអង្គការសហប្រជាជាតិ ប៉ុន្តែសមាសភាពនៃក្រុមប្រឹក្សានេះ មិនទាន់បានឯកភាពគ្នាពេញលេញនៅឡើយ។

ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៨៩ ការចាប់ផ្តើមសន្និសីទទីក្រុង"បារីស"(paris) រយៈពេលមួយខែ ស្តីអំពីកម្ពុជា មានការចូលរួមពីប្រទេសចំនួន១៩ រដ្ឋកម្ពុជា ក្រុមត្រីភាគី ក្រោមអធិបតីភាពលោក រ៉ូឡង់ ឌុយមាស់ មេដឹកនាំបារាំង និង លោក អាលី អាឡាតាស្ស មេដឹកនាំឥណ្ឌូនេស៊ី ។ នៅថ្ងៃទី៧-១៥ ខែសីហា ឆ្នាំ១៩៨៩ ក្រុមការងារស្វែងរកការពិតរបស់អង្គការសហប្រជាជាតិ ដែលមានសមាជិកចំនួន ១៥ រូបបានមកដល់ទីក្រុងភ្នំពេញ ដើម្បីប្រមូលព័ត៌មានចាំបាច់ផ្តល់ឱ្យសន្និសីទប៉ារីសក្នុងករណីដែលអង្គការសហប្រជាជាតិត្រូវធ្វើប្រតិបត្តិការនៅកម្ពុជា។ នៅខែកញ្ញា គេសង្កេតឃើញថា មុនពេលថ្ងៃដែលវៀតណាមប្រកាសដកកម្លាំងយោធារបស់ខ្លួនចុងក្រោយពីកម្ពុជា ប្រជាជនវៀតណាមមួយចំនួន បាននាំគ្នាវិលត្រឡប់ទៅប្រទេសវិញ ដោយខ្លាចមានការសងសឹក។ ថ្ងៃ២១-២៦ ខែកញ្ញា កងទ័ពវៀតណាមលើកចុងក្រោយ រួមមានគណៈបញ្ជាការ រណសិរ្ស៤៧៩, ៥៧៩, ៧៧៩, ៩៧៩, ៣០២,

៣៣០ តំបន់៩ដើងទឹក, វរសេនាធំទ័ពអាកាស៩០១, កងវរៈក្រោះរថពាសដែក កាំភ្លើងធំ កាំភ្លើងការពារអាកាសសរុប ២៦ ០០០នាក់ បានដកថយចេញពីកម្ពុជា ទោះបីមតិអន្តរជាតិមួយចំនួនមិនបានយល់ស្រប ដោយសារតែពួកគេលើកឡើងថា គ្មានយន្តការត្រួតពិនិត្យជាលក្ខណៈអន្តរជាតិក៏ដោយ។ ឆ្លើយតបមតិអន្តរជាតិមួយចំនួន លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៃរដ្ឋកម្ពុជា ស្នើសុំឲ្យលោកអគ្គលេខាធិការអង្គការសហប្រជាជាតិបញ្ជូនបេសកកម្មមួយមកស្រុកខ្មែរ ដើម្បីពិនិត្យមើលស្ថានភាពនៃការដកកងទ័ពវៀតណាម ទាំងអស់ចេញពីប្រទេសកម្ពុជា។ នៅ ថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៨៩ វិមាន"បង់តាហ្គោន" (ក្រសួងការពារជាតិ និងសេនាធិការដ្ឋានអាម៉េរិក)បានសន្និដ្ឋានថា កងទ័ពវៀតណាមពិតជា បានដកចេញពីកម្ពុជា។

អ្នកប្រវត្តិសាស្ត្រមួយចំនួនបានលើកឡើងថា ការដកថយចុងក្រោយនៃកងទ័ពវៀតណាមនេះគឺជាចុងបញ្ចប់នៃសង្គ្រាមឥណ្ឌូចិនលើកទី៣ ។ ប៉ុន្តែការយល់ឃើញរបស់យើងថា កិច្ចព្រមព្រៀងក្រុងប៉ារីសឆ្នាំ១៩៩១ ព្រោះវានៅមានជាប់ទាក់ទងនឹងខ្លឹមសារផ្នែកទី៤ នៃកិច្ចព្រមព្រៀងក្រុងប៉ារីសទាក់ទងនឹងអធិបតេយ្យ និងបូរណភាពដែនដីកម្ពុជា ជាមួយនឹងកិច្ចសន្យាប្រទេសជិតខាង និងមហាអំណាចផងដែរ។

ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៨៩ ផែនការសន្តិភាពថ្មីមួយត្រូវបានលើកឡើងដោយរដ្ឋមន្ត្រីអូស្ត្រាលី(Gareth Evans) ក្នុងខណៈពេលដែលក្រុមអ្នកតស៊ូ ជាពិសេស កងទ័ពសីហនុនិយមវាយយកតំបន់ភ្នំស្រុក ក្នុងខេត្តបន្ទាយមានជ័យ ចំណែកកងទ័ពរណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរ បានវាយយកតំបន់ថ្មពួក ស្វាយចេក រីឯខ្មែរក្រហមវាយយកប៉ៃលិននិងតំបន់ផ្សេងៗទៀត។

សមាជិកអចិន្ត្រៃយ៍ទាំង៥នៃក្រុមប្រឹក្សាសន្តិសុខ អង្គការសហប្រជាជាតិជួបគ្នា នៅញ៉ូវយ៉ក នាថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៨៩ ដើម្បីពិភាក្សាគ្នាអំពីបញ្ហាកម្ពុជា ដោយបានស្នើឲ្យអង្គ

ការសហប្រជាជាតិ ដើរតួនាទីយ៉ាងសំខាន់ក្នុងការរកដំណោះស្រាយវិបត្តិកម្ពុជានិងបង្កើតក្រុមប្រឹក្សាជាតិជាន់ខ្ពស់ (Conscil National Supreme ឬ SNC) ក្នុងន័យដើរតួនាទីជាតំណាងអធិបតីភាពប្រទេស កម្ពុជាក្នុងរយៈពេលអន្តរកាល ។ មហាសន្និបាតអង្គការសហប្រជាជាតិ ចាត់ទុកវៀតណាមថា បានដកទ័ពចេញពីកម្ពុជាមែន ប៉ុន្តែមិនបានចេញសេចក្តីប្រកាសជាផ្លូវការទេ ព្រោះក្នុងកំឡុងពេលដកកងទ័ពនោះ ពុំមានការរៀបចំអ្នកត្រួតពិនិត្យអន្តរជាតិផ្លូវការណាមួយ។ មហាសន្និបាត របស់ អ.ស.ប. ចេញសេចក្តីសម្រេចថ្មី លេខ 44/22 ដោយសម្លេងឆ្នោត ១២៤គាំទ្រ ទល់នឹង១៧ប្រឆាំង និងអនុប្បវាទ ១២ សម្លេង សំដៅអំពាវនាវឱ្យមានការដោះស្រាយបញ្ហាកម្ពុជា ឱ្យទូលំទូលាយ ដោយគ្មានការវិលត្រឡប់ទៅកាន់អំណាចរបស់ខ្មែរក្រហម។

នៅ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩៨៩ រដ្ឋមន្ត្រីការបរទេសអូស្ត្រាលី Gareth Evans លើកស្នើគម្រោងផែនការសន្តិភាពមួយចំពោះមុខព្រឹទ្ធសភាអូស្ត្រាលី។ គម្រោងនេះមានទិសដៅដោះស្រាយឧបសគ្គដែលកំពុងជួបប្រទះគឺ បញ្ហារដ្ឋាភិបាលអន្តរកាល សមាសភាព និងតួនាទីរបស់រដ្ឋាភិបាលនេះ។ គម្រោងនេះស្នើឱ្យមានរដ្ឋការបណ្តោះអាសន្នមួយនៅក្រោមការដឹកនាំផ្ទាល់របស់អង្គការសហប្រជាជាតិ រហូតដល់មានការបោះឆ្នោតជាសាកល។ សម្តេចនរោត្តម សីហនុ ថ្លែងថា ព្រះអង្គយល់ស្របនឹងចំណុចមួយចំនួននៃផែនការសន្តិភាពរបស់ប្រទេសអូស្ត្រាលីនេះ ហើយ លោក ហ៊ុន សែន ក៏បានប្រកាសថា អាចជជែកគ្នាលើផែនការរបស់រដ្ឋមន្ត្រីការបរទេសអូស្ត្រាលី Gareth Evans។ ចំណែក លោក អាលី អាឡាតាស្ស រដ្ឋមន្ត្រីការបរទេសឥណ្ឌូនេស៊ី ប្រកាសនា ថ្ងៃទី៣០ ខែធ្នូ ថា នឹងមានការបើកសន្និសីទមួយនៅខែកុម្ភៈ ឆ្នាំ១៩៩០ ដើម្បីពិភាក្សាអំពីផែនការសន្តិភាពរបស់ប្រទេសអូស្ត្រាលី។

នៅថ្ងៃទី៣ ខែមករា ឆ្នាំ១៩៩០ លោក កាស្តេឡូ អនុរដ្ឋមន្ត្រីការបរទេសអូស្ត្រាលី មកទីក្រុងបាងកក បង្ហាញផែនការសន្តិភាព អូស្ត្រាលីដល់រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ និងបង្ហាញដល់លោក ហ៊ុន សែន នាក្រុងភ្នំពេញ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៩០។

នៅទីក្រុងប៉ារីសប្រទេសបារាំង នា ថ្ងៃទី១១ ខែមករា ឆ្នាំ១៩៩០ លោកប្រធានាធិបតីបារាំង លោកហ្វ្រង់ស្វ័រ មីត្តេរ៉ង់ បានប្រកាសថា ការស្រុះស្រួលជាមួយពួកខ្មែរក្រហមដើម្បីរៀបចំផែនការសន្តិភាពមិនទទួលបានជោគជ័យទេ។ យ៉ាងណា ថ្ងៃទី១៥-១៧ខែមករា ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ នៅតែបន្ត រួមប្រជុំគ្នានៅទីក្រុង ប៉ារីស ដើម្បីពិភាក្សាអំពីផែនការសន្តិភាពអូស្ត្រាលី ហើយស្វែងរកមូលដ្ឋានដើម្បីឲ្យអង្គការសហប្រជាជាតិ ធ្វើអន្តរាគមន៍បញ្ចប់បញ្ហាជម្លោះនៅកម្ពុជា។

នៅថ្ងៃទី១១-១២ខែកុម្ភៈ ឆ្នាំ១៩៩០ មានកិច្ចប្រជុំលើកទី២ នៅទីក្រុងញូវយ៉ក និងមានអង្គប្រជុំក្រៅផ្លូវការមួយនៅទីក្រុងហ្សាការតា ឥណ្ឌូណេស៊ី ក្រុមប្រឹក្សាសន្តិសុខបានសម្រេចបង្កើតកម្លាំងសន្តិសុខសម្រាប់ធ្វើអន្តរាគមន៍នៅកម្ពុជានិងមានអង្គប្រជុំក្រៅផ្លូវការមួយ ដើម្បីពិភាក្សាអំពីបែបបទធ្វើអន្តរាគមន៍ស៊ីវិល និងយោធារបស់អង្គការសហប្រជាជាតិពោលគឺអង្គការអាប្រូនុច(APRONUC) ដែលមានន័យថា អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិនៅកម្ពុជា។ ក្រោយសម័យប្រជុំលើកទី២ នៅទីក្រុងញូវយ៉កក្រុមប្រឹក្សាសន្តិសុខ បានបញ្ជាក់ពីអនាគតបេសកកម្មរបស់អង្គការសហប្រជាជាតិនៅប្រទេសកម្ពុជាឈានមកដល់កិច្ចព្រមព្រៀងមួយ ដែលមានទាំងអស់៤ចំណុចៈ ទី១ផ្ទៀងផ្ទាត់ការដកកងទ័ពវៀតណាម ទី២តម្រូវឱ្យទទួលយកការឈប់បាញ់គ្នា ទី៣ត្រួតពិនិត្យការបញ្ឈប់ការផ្តល់ជំនួយ និងប្រគល់គ្រឿងអាវុធដល់ភាគីជម្លោះ ទី៤ការប្រមូលផ្តុំនៅក្នុងបន្ទាយនៃកម្លាំងទ័ពក្នុងតំបន់ផ្សេងៗ។

សម្តេចនរោត្តម សីហនុ និងលោក ហ៊ុន សែន បានមកជួបគ្នានៅក្រុងបាងកក នាថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ១៩៩០ ដែលជំនួបនេះរៀបចំដោយនាយករដ្ឋមន្ត្រីថៃ Chatchai Chunhawan និងឧត្តមសេនីយ៍ឯក Chawalit Yongchaiyut ដើម្បីពិភាក្សាយល់ព្រមគ្នាអំពីការដាក់កំលាំងទ័ពអង្គការសហប្រជាជាតិនៅកម្ពុជាតាមកម្រិតមួយឲ្យបានសមស្រប និងអំពីការបង្កើតអង្គការកំពូលមួយ សម្រាប់តំណាងអធិបតេយ្យភាព និង ឯកភាពជាតិនៃប្រទេសកម្ពុជា។ នៅពេលវិលត្រឡប់ពីបាងកកមករាជធានីភ្នំពេញវិញ លោកនាយករដ្ឋមន្ត្រីហ៊ុន សែន បានប្រាប់អ្នកកាសែតថា លោកនឹងមិនអនុញ្ញាតឱ្យរដ្ឋាភិបាលរបស់លោកត្រូវបានរំលាយមុនការបោះឆ្នោតទេ ។

នៅថ្ងៃទី២៦-២៨ខែកុម្ភៈ ឆ្នាំ១៩៩០ កិច្ចប្រជុំក្រៅផ្លូវការនៅហ្សាកាតា លើកទី៣ JIM III (Jakarta informal Meeting III) បានធ្វើបទបង្ហាញសៀវភៅក្រហម របស់អូស្ត្រាលី ស្តីពីបែបបទអន្តរាគមស៊ីវិល និងយោធារបស់អង្គការសហប្រជាជាតិ)។ អង្គប្រជុំលើកទី៣ នាថ្ងៃទី១២-១៣ខែមីនា ឆ្នាំ១៩៩០ នៅទីក្រុងប៉ារីស នៃប្រទេសមហាអំណាចទាំង៥ ដើម្បីរៀបចំការបោះឆ្នោតនៅកម្ពុជា និងបានស្នើឲ្យអាសនៈខ្មែរនៅអង្គការសហប្រជាជាតិត្រូវប្រគល់ទៅក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ប៉ុន្តែសមាសភាពនៃក្រុមប្រឹក្សាជាតិសម្រាប់គ្រប់គ្រងប្រទេសកម្ពុជា ត្រូវកំណត់ដោយភាគីខ្មែរទាំង៤។ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩០ អង្គការសហប្រជាជាតិបានបញ្ជូនបេសកជនបច្ចេកទេសមកប្រទេសកម្ពុជាជាថ្មី ដើម្បីពិនិត្យមើលទិដ្ឋភាពនៃការងាររដ្ឋបាល និងវាយតម្លៃលើតម្រូវការដាក់ស្តែង សម្រាប់ប្រតិបត្តិការរបស់អង្គការសហប្រជាជាតិនាពេលអនាគតក្នុងប្រទេសកម្ពុជា។ សម្តេចនរោត្តមសីហនុ នាថ្ងៃទី៩ ខែមេសា ឆ្នាំ១៩៩០ បានបង្ហាញពីកម្មវិធីសន្តិភាពថ្មីចំនួនប្រាំមួយចំណុចរបស់កម្ពុជា ហើយដែលក្នុងនោះកម្លាំងយោធារបស់អង្គការសហប្រជាជាតិមានអំណាចទាំងពេលមុន និងក្នុងអំឡុងពេលបោះឆ្នោតទូទៅដើម្បីបង្កើតរដ្ឋាភិបាលថ្មី។

នៅក្នុងកំឡុងខែមេសា ឆ្នាំ១៩៩០ ខ្មែរក្រហមបង្កើនការវាយប្រហារដោយយោធាលើតំបន់នានានៅភាគខាងជើង ភាគខាងលិច នៃប្រទេសកម្ពុជា។ នៅថ្ងៃទី ៣ ខែឧសភា ឆ្នាំ១៩៩០ សម្ដេចនរោត្ដម សីហនុ បានស្នើឱ្យរដ្ឋាភិបាលក្រុងភ្នំពេញ ដាក់ទីក្រុងភ្នំពេញ ជាទីក្រុងដែលគ្មានកងទ័ព និងជាទីក្រុងបើកចំហ ហើយនឹងត្រូវបានដាក់ក្រោមរដ្ឋបាលរបស់អង្គការសហប្រជាជាតិ។

នាថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩០ អង្គប្រជុំលើកទី៤ របស់ អ.ស.ប.នៅទីក្រុងញូវយ៉ក។ អគ្គលេខាធិការរងអង្គការសហប្រជាជាតិ បញ្ជាក់លក្ខខណ្ឌអប្បរមា ដើម្បីអង្គការសហប្រជាជាតិចូលរួមត្រួតពិនិត្យការឈប់បាញ់ ការឈប់ឱ្យមានជំនួយពីខាងក្រៅដល់ភាគីនីមួយៗ ការបោះឆ្នោតដោយសេរីក្រោមការចាត់ចែងរបស់អង្គការសហប្រជាជាតិ ការបង្កើតរបបនយោបាយមួយដែលគោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ហើយសហគមន៍អន្តរជាតិធានាឯករាជ្យភាពបូរណភាពទឹកដី អព្យាក្រឹត និងឯកភាពជាតិកម្ពុជា។

មេដឹកនាំសហរដ្ឋអាម៉េរិក និងមេដឹកនាំសូវៀត បានគាំទ្រ សម្ដេចនរោត្ដម សីហនុ ដែលបានក្លាយជាដឹកនាំរដ្ឋាភិបាលជាតិកម្ពុជា។ ប៉ុន្តែជំនួបនៅប្រទេសជប៉ុន ក្រុមខ្មែរក្រហមជំទាស់នឹងរូបមន្តបែងចែកសមាជិក ក្នុងក្រុមប្រឹក្សាជាតិជាន់ខ្ពស់ដែលមាន១២នាក់ ដោយចែកជាពីរស្មើគ្នាគឺ៦+៦ក្នុងន័យរដ្ឋកម្ពុជាត្រូវមានសមាជិក៦រូប ហើយភាគីរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យក៏មាន៦រូប ប៉ុន្តែខ្មែរក្រហមទាមទារយកសមាជិក១២រូបចែកនឹង៤ភាគីវិញ។

នៅ ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ១៩៩០ មេដឹកនាំសហភាពសូវៀត Igor Rogachev, បានធ្វើដំណើរទៅទីក្រុងប៉េកាំង ដើម្បីចរចាជាមួយលោករដ្ឋមន្ត្រីការបរទេសចិនអំពីផែនការសន្តិភាពនៅកម្ពុជាបន្ថែមទៀត។ ចំណែកលោកប៊ូស ប្រធានាធិបតីសហរដ្ឋអាម៉េរិកបានជួបពិភាក្សាជាមួយមេដឹកនាំថៃ ក្នុងការប្ដេជ្ញាចិត្តបង្កើតឱ្យមានការបោះឆ្នោតដោយសេរី និង

យុត្តិធម៌ក្រោមការឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ និងដោយមានវត្តមានកងកម្លាំងរក្សាសន្តិភាពអន្តរជាតិ"នៅកម្ពុជា។

នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៩០ លោក"ជេមបេកគែរ" (Jame Baker) រដ្ឋ មន្ត្រីការបរទេសសហរដ្ឋអាម៉េរិក បានប្រកាសថា សហរដ្ឋអាម៉េរិក ឈប់គាំទ្ររដ្ឋាភិបាលត្រីភាគីកម្ពុជាប្រជាធិបតេយ្យនៅអង្គការសហប្រជាជាតិទៀតហើយ មិនតែប៉ុណ្ណោះសហរដ្ឋអាម៉េរិកស្នើសុំធ្វើកិច្ចចរចាជាមួយក្រុងហាណូយ និងក្រុងភ្នំពេញផ្ទាល់ ក្នុងការស្វែងរកដំណោះស្រាយវិបត្តិនៅកម្ពុជា មានន័យថា ចង់ដើរតួរតែម្នាក់ឯងក្នុងការដោះស្រាយបញ្ហាកម្ពុជា។ បញ្ហានេះបានធ្វើឱ្យរដ្ឋមន្ត្រីការបរទេសអាស៊ានអំពាវនាវឱ្យភាគីកម្ពុជាទាំង៤ប្រជុំគ្នា ដើម្បីចាត់តាំងក្រុមប្រឹក្សាជាតិជាន់ខ្ពស់មួយ ហើយសម្តែងការសោកស្តាយ ចំពោះគោលជំហរដែលសហរដ្ឋអាម៉េរិកបានប្រកាសខាងលើនេះ។ ថ្ងៃទី៥-៦ ខែសីហា មន្ត្រីអាម៉េរិក និងវៀតណាមបានជួបគ្នានៅទីក្រុងញូវយ៉កដើម្បីពិភាក្សាអំពីសន្តិភាពនៅកម្ពុជា និងបានប្រកាសថាការចរចាររវាងសហរដ្ឋអាម៉េរិក និងកម្ពុជា នឹងធ្វើនៅវៀងច័ន្ទ ប្រទេសឡាវ។

ថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩០ ក្រុមអ្នកតស៊ូទាំង៣ក្រុម បានប្រកាសត្រៀមខ្លួនជាស្រេចដើម្បីចរចាជាមួយរដ្ឋកម្ពុជា ក្នុងការបង្កើតក្រុមប្រឹក្សាជាតិជាន់ខ្ពស់ដែលជាអង្គការស្របច្បាប់តែមួយគត់ និងជាប្រភពនៃអំណាចនៃកម្ពុជាក្នុងរយៈកាលអន្តរកាល។

នៅថ្ងៃទី២៧-២៨ខែសីហា ឆ្នាំ១៩៩០ កិច្ចប្រជុំលើកទី៦ របស់ក្រុមប្រឹក្សាសន្តិសុខ អ.ស.ប នៅ"ញ៉ូវយ៉ក"ក្នុងឱកាសនោះមានការអនុម័តផែនការទូទៅមួយ ដែលត្រូវដោះស្រាយជម្លោះនៅកម្ពុជា។ ផែនការនោះគឺកម្ពុជាត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរដ្ឋបាលពីសំណាក់ អ.ស.ប ក្នុងរយៈពេលអន្តរកាលមួយ ។ រដ្ឋាភិបាលជាតិចម្រុះគាំទ្រផែនការនេះ តែរដ្ឋកម្ពុជានៅមានមន្ទិលសង្ស័យលើគោលជំហររបស់អង្គការសហប្រជាជាតិ តើមានលម្អៀងឬទេ? តើដកអាវុធពីខ្មែរក្រហមបានឬទេ?។ នាថ្ងៃទី៩-១០ ខែកញ្ញា ឆ្នាំ១៩៩០ ការប្រជុំក្រៅផ្លូវ

ការលើកទី៤ JIM IV នៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូណេស៊ី ដើម្បីឲ្យអ្នកតំណាងគូភាគីខ្មែរទាំង៤ ពិនិត្យមើលលើឯកសារដែលប្រទេសមហាអំណាចទាំង៥នៃក្រុមប្រឹក្សាសន្តិសុខ បានស្នើឡើងកាលពីថ្ងៃទី២៧ និង២៨ ខែសីហា ឆ្នាំ១៩៩០ ជាពិសេសព្រមព្រៀងគ្នាបង្កើតក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា (SNC) ដែលជាស្ថាប័នស្របច្បាប់ និងជាប្រភពនៃអំណាចតែមួយគត់ក្នុងតំណាក់កាលអន្តរកាល ដើម្បីឈានទៅដោះស្រាយបញ្ហាកម្ពុជា។ ក្រុមជម្លោះទាំង៤ភាគី នៅកម្ពុជាបានបន្តជួបគ្នានៅទីក្រុងបាងកកដើម្បីបង្កើតក្រុមប្រឹក្សាជាតិជាន់ខ្ពស់ (SNC) នាថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៩០។ សមាជិក SNC ចំនួន១២រូបត្រូវបានស្នើឡើងតែមិនទាន់ឯកភាពគ្នានៅឡើយ។ នៅខែតុលា អាសនៈកម្ពុជានៅអង្គការសហប្រជាជាតិ ត្រូវបានសម្រេចទុកឱ្យនៅទំនេរ ដើម្បីងាយស្រួលដល់ការដោះស្រាយបញ្ហាកម្ពុជា។ ការធ្វើបែបនេះក្នុងគោលដៅជំរុញឱ្យភាគីជម្លោះដោះស្រាយបញ្ហាសមាជិកក្នុងក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា។ ថ្ងៃទី២៥-២៦ខែវិច្ឆិកា ឆ្នាំ១៩៩០ នាទីក្រុងប៉ារីស ផែនការដែលជាសេចក្តីព្រមព្រៀងដោយសមាជិក អចិន្ត្រៃយ៍ទាំង ៥ បានត្រូវបញ្ជូលទៅឲ្យបណ្តាភាគីពាក់ព័ន្ធជាផ្លូវការ និងបានបើកអង្គប្រជុំពិភាក្សាលំអិតថែមទៀត អំពីការដោះស្រាយទំនាស់នយោបាយទូទៅ ដោយរក្សាខ្ជាប់នូវមូលដ្ឋាននៃផែនការក្របខ័ណ្ឌដែលត្រូវបានកំណត់នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៩០។

ថ្ងៃទី៥ ខែមករា ឆ្នាំ១៩៩១ រដ្ឋាភិបាលរដ្ឋកម្ពុជាប្រកាសថា គេមិនអាចទុកចិត្តខ្មែរក្រហមបានទេនៅក្នុងពេលអន្តរកាល។ រដ្ឋកម្ពុជាដាច់ខាតមិនព្រមរំលាយរដ្ឋការ និងកងទ័ពរបស់ខ្លួនមុនការបោះឆ្នោតទេ។ សហប្រធានទាំង២នៃសន្និសីទទីក្រុងប៉ារីស(ប្រទេសបារាំង ឥណ្ឌូនេស៊ី) និង អគ្គលេខាធិការអង្គការសហប្រជាជាតិប្រកាសឲ្យភាគីខ្មែរទាំងអស់ឱ្យឈប់បាញ់គ្នាចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ១៩៩១។ នៅក្រុងបាងកក លោក ហ៊ុន សែន, លោក ខៀវ សំផន, ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ និងលោក សឺន សាន ក្នុងឱកាសជួប

ជាមួយនាយករដ្ឋមន្ត្រីថៃ គឺលោក អាណាន់ ប៉ាន់យ៉ារ៉ាឈុន ភាគីទាំងអស់ប្រកាសយល់ព្រមឈប់បាញ់។ ថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៩១ មានការបង្កើតគណៈកម្មាការបច្ចេកទេសមួយ ដើម្បីពិនិត្យការឈប់បាញ់។

នៅ ថ្ងៃទី៤-៥ ខែឧសភា ឆ្នាំ១៩៩១ ជំនួបក្រៅផ្លូវការនៅហ្សាការតាលើកទី៥ (JIM V) ស្តីពីបញ្ហាកម្ពុជា។ ភាគីក្រុងភ្នំពេញ និងសម្តេចនរោត្តម សីហនុ ព្រមព្រៀងគ្នាអំពីប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា តែខ្មែរក្រហមជំទាស់។ ប្រទេសថៃស្នើចិនឲ្យគាបសង្កត់លើខ្មែរក្រហមដើម្បីឲ្យខ្មែរក្រហមចេះបត់បែនតាមស្ថានការណ៍។ ថ្ងៃទី២៤-២៦ខែមិថុនា ឆ្នាំ១៩៩១ កិច្ចប្រជុំរបស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា /SNC នៅ"ប៉ាតាយ៉ា"(Pattaya) ប្រទេសថៃ សេចក្តីសម្រេចគឺត្រូវឲ្យមានការឈប់បាញ់គ្នាដោយគ្មានកំណត់ ឈប់ទទួលជំនួយយោធាពីបរទេស ហើយក្រុមប្រឹក្សាជាតិជាន់ខ្ពស់ត្រូវតែបោះទីតាំងនៅទីក្រុង ភ្នំពេញចាប់ពីខែវិច្ឆិកា។ នៅថ្ងៃទី១៦-១៧ខែកក្កដា ឆ្នាំ១៩៩១ មានប្រជុំក្រុមប្រឹក្សាជាតិជាន់ខ្ពស់/SNCនៅទីក្រុង"ប៉េកាំង" ដោយជ្រើស តាំងសម្តេចនរោត្ត សីហនុ ជាប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ហើយព្រះអង្គបង្កើតគណប្រតិភូតែមួយទៅតំណាងកម្ពុជានៅ អង្គការសហប្រជាជាតិ។ សម្តេចនរោត្តម សីហនុ និងលោក ហ៊ុន សែន ទៅធ្វើទស្សនៈកិច្ចជាផ្លូវការប្រទេសកូរ៉េខាងជើងនាថ្ងៃទី២០-២១ខែកក្កដា ឆ្នាំ១៩៩១ ហើយនៅថ្ងៃទី២២-២៤ខែកក្កដា ប្រទេសចិនបានទទួលលោក ហ៊ុន សែន យ៉ាងអធិកអធមនៅក្នុងក្របខ័ណ្ឌនៃទស្សនកិច្ចជាផ្លូវការមួយ។ បញ្ហានេះបាននាំទៅដល់ការលើកឡើងរបស់សហរដ្ឋអាម៉េរិកថា សូមឲ្យមានការប្រុងប្រយ័ត្នចំពោះការដោះស្រាយបញ្ហាកម្ពុជា ព្រោះភាគីខ្វះនៃអធិករណ៍ខ្មែរថា ទីក្រុងប៉េកាំងធ្លៀតយក "ដំណោះស្រាយខ្មែរក្រហម" មកជំនួស។ នៅទីក្រុងបាងកក លោក សូឌុចសិន អនុរដ្ឋមន្ត្រីការបរទេសចិន ធ្វើការកែតម្រូវថាដំណោះស្រាយអធិករណ៍ខ្មែរដែលកំពុងដំណើការមិនមែនជាដំណើការដំណោះស្រាយខ្មែរក្រហមទេ។

*ការជួបប្រជុំគ្នានៅ "ប៉ាតាយ៉ា" នាចុងខែសីហា ឆ្នាំ១៩៩១ ភាគីកម្ពុជាទាំងអស់បានសម្រេចរំសាយកងទ័ព ៧០% ហើយ ៣០% ដែលនៅសល់ត្រូវបញ្ចូលឲ្យនៅតាមបន្ទាយ ។*

*ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩១ រដ្ឋមន្ត្រីការបរទេសវៀតណាម និងចិនបានជួបគ្នានៅទីក្រុងប៉េកាំងដើម្បីនិយាយឲ្យច្បាស់ម្តងទៀតអំពី ការដាក់ទំនាក់ទំនងគ្នាជាប្រក្រតីឡើងវិញរវាងប្រទេសកុម្មុយនីស្តទាំង២ ហើយសុខចិត្តទទួលយកផែន ការសន្តិភាពនៅកម្ពុជា។*

*ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៩១ ជំនួបរវាងសម្តេចនរោត្តមសីហនុ និងលោក ហ៊ុន សែន នៅក្រុងញ៉ូយ៉ក គឺពេលនោះហើយដែលក្រុមប្រឹក្សាជាតិជាន់ខ្ពស់ បានទទួលអាសនៈនៅអង្គការសហប្រជាជាតិ។ នៅថ្ងៃទី១៦ ខែតុលាឆ្នាំ១៩៩១ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ សម្រេចបង្កើតមីប្រេនុច* MIPRENUC *(បេសកកម្មត្រៀមរៀបចំកម្លាំងអង្គការសហប្រជាជាតិនៅកម្ពុជា) ឬភាសាអង់គ្លេសហៅថា* (UNAMIC) *ដើម្បីត្រៀមភារកិច្ចពេលណាមានកិច្ចព្រៀមព្រៀងដោះស្រាយបញ្ហាកម្ពុជា។*

## ៣.កិច្ចព្រមព្រៀងក្រុងប៉ារីស

*នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្រុងប៉ារីសស្តីពីសន្តិភាពនៅកម្ពុជា។ ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះមាន១៩ប្រទេសចូលរួម(ទី១ ភាគីកម្ពុជា (ដែលមកពីខ្មែរ៤ភាគី) ទី២សមាជិកអចិន្ត្រៃយ៍ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ(អាមេរិក អង់គ្លេស បារាំង(សហប្រធានសន្និសីទ) ចិន និងសហភាពសូវៀត ទី៣ ប្រទេសនៅអាស៊ីអាគ្នេយ៍(ឥណ្ឌូណេស៊ី (សហប្រធានសន្និសីទ) វៀតណាម ឡាវ ថៃ សិង្ហបុរី ម៉ាឡេស៊ី ហ្វីលីពីន និងប្រ៊ុយណេ) ទី៤ក្រុមប្រទេសមិនចូលបក្សសម្ព័ន្ធតំណាងដោយយូហ្គោស្លាវី និងទី៥មានប្រទេស៤ផ្សេងទៀតគឺ ឥណ្ឌា ជប៉ុន កាណាដា និងអូស្ត្រាលី ។*

**៣.១.ខ្លឹមសារសំខាន់ៗកិច្ចព្រមព្រៀងក្រុងប៉ារីសមាន៤ចំណុចសំខាន់គឺ ៖**

**ចំណុចសំខាន់ទី១** ៖ *ការបូកសរុបលទ្ធផលនៃសន្និសីទក្រុងប៉ារីសស្តីពីកម្ពុជា ដែលបានធ្វើឡើងពីខែកក្កដា ឆ្នាំ១៩៨៩ ដល់ខែតុលា ឆ្នាំ១៩៩១។*

**ចំណុចសំខាន់ទី២** ៖ *កិច្ចព្រមព្រៀងលើដំណោះស្រាយបញ្ហាជម្លោះនយោបាយនៅកម្ពុជា ដែលមានខ្លឹមសារសរុបថា កិច្ចព្រមព្រៀងបានផ្តល់សិទ្ធិអំណាចដល់អ.ស.ប. ក្នុងការត្រួតពិនិត្យបទឈប់បាញ់របស់ភាគីជម្លោះទាំង៤ភាគី បញ្ជូនខ្មែរដែលគ្មានទីលំនៅតាមបណ្តោយព្រំដែនជាមួយប្រទេសថៃឱ្យមានទីលំនៅក្នុងប្រទេសវិញ ដកហូតអាវុធកងយោធាពីគ្រប់ភាគី និងរៀបចំប្រទេសសម្រាប់ការបោះឆ្នោតដោយសេរីនិងយុត្តិធម៌សម្រាប់ភាគីទាំង៤។*

*ក្រោយចុះហត្ថលេខា បើភាគីជម្លោះទាំង៤ក្នុងប្រទេសកម្ពុជា មិនសុខចិត្ត អាចសើរើបានដោយយោងតាមមាត្រា២៩នៃកិច្ចព្រមព្រៀងទី២ (ស្តីពីការដោះស្រាយជម្លោះផ្ទៃក្នុងកម្ពុជា) ហើយអ្នកដែលអាចកោះប្រជុំបាន គឺសហប្រធាននៃសន្និ សីទក្រុងប៉ារីស (បារាំង និងឥណ្ឌូណេស៊ី) ក៏ប៉ុន្តែ ការកោះប្រជុំនេះអាចធ្វើទៅបានលុះត្រាតែមានសំណើពីអគ្គលេខាធិការអង្គការសហប្រជាជាតិ (អ.ស.ប)។*

**ចំណុចសំខាន់ទី៣** ៖ *ចែងអំពីការគោរពឯករាជ្យអធិបតេយ្យ បូរណភាព និងអព្យាក្រឹតរបស់កម្ពុជា។ តាមរយៈកិច្ចព្រមព្រៀងនេះ កម្ពុជានិងប្រទេសជាហត្ថលេខីផ្សេងទៀត មានកាតព្វកិច្ចគោរពឯករាជ្យ អធិបតេយ្យ បូរណភាព និងអព្យា ក្រឹតគ្នាទៅវិញទៅមក ។*

បើក្នុងការណីមានការរំលោភលើចំណុចទី៣នេះ ភាគីនីមួយអាចប្ដឹងតវ៉ា ដោយយោងលើ មាត្រា៩នៃចំណុចទី៣នេះ ដែលចែងថា ៖

១-នៅក្នុងករណីមានការរំលោភ ឬគំរាមរំលោភអធិបតេយ្យ ឯកពជ្យ បូរណភាព (...) ហត្ថលេខីនៃកិច្ចព្រមព្រៀងត្រូវធ្វើការប្រជុំជាបន្ទាន់ ដើម្បីចាត់វិធានការសមស្រប (...)

២-ការចាត់នូវវិធានការសមស្របទាំងនេះ អាចជាការប្ដឹងទៅក្រុមប្រឹក្សាសន្តិសុខ អ.ស.ប ឬវិធានការផ្សេងទៀត ដែលមានចែងក្នុងមាត្រា៣៣នៃធម្មនុញ្ញសហប្រជាជាតិ

៣.ភាគីនានានៃកិច្ចព្រមព្រៀងនេះក៏អាចអំពាវនាវឱ្យសហប្រធានសន្និសីទក្រុងប៉ារីសស្ដីពីកម្ពុជា ដើម្បីដោះស្រាយបញ្ហាទាំងនេះផងដែរ។

៤.នៅក្នុងករណីមានការរំលោភសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា គេអាចអំពាវនាវឱ្យស្ថាបនមានសមត្ថកិច្ចរបស់អង្គការសហប្រជាជាតិចាត់វិធានការសមស្របដើម្បីដោះស្រាយបញ្ហាទាំងនេះ ។

**ចំណុចសំខាន់ទី៤៖** ចែងស្ដីអំពីការកសាងបទេសកម្ពុជាឡើងវិញ។ តាមរយៈសេចក្ដីថ្លែងការណ៍នេះ ប្រទេសហត្ថលេខីសន្យាផ្ដល់ជំនួយ ដើម្បីជួយស្ដារនិងអភិវឌ្ឍប្រទេសកម្ពុជាឡើងវិញ។

## ៣.២.ការអនុវត្តកិច្ចព្រមព្រៀងក្រុងប៉ារីស

គួរបញ្ជាក់ថាមុនពេលអនុវត្តកិច្ចព្រមព្រៀងក្រុងប៉ារីស នៅ ថ្ងៃទី៥-៧ ខែវិច្ឆិកា ឆ្នាំ១៩៩១ អគ្គលេខាគណបក្សកុម្មុយនីស្តវៀតណាម ដោយមាននាយករដ្ឋមន្ត្រី វ៉ូវ៉ាន់គៀត (Vo van Kiet) រួមដំណើរផងបានធ្វើដំណើរទៅក្រុងប៉េកាំង ដើម្បីភ្ជាប់ទំនាក់ទំនងការទូតជាថ្មី

វិញ ជាមួយនឹងប្រទេសចិនប្រជាមានិត ដែលនេះយើងយល់ថា ជាសញ្ញាបញ្ជាក់ថា សង្គ្រាមឥណ្ឌូចិនលើកទី៣។

ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៩១ MIPRENUCចាប់ផ្តើមធ្វើការនៅកម្ពុជា ខាងផ្នែកការងារស៊ីវិលដែលមាន អ្នកការទូតបង់ក្លាដែស ឈ្មោះ អាប់ឌុល ការីម ជាអ្នកដឹកនាំ។ ការងារខាងយោធាឧត្តមសេនីយ៍បារាំងឈ្មោះឡូរីដុងជាអ្នកដឹកនាំ។ ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៩១ លោក ហ៊ុន សែន បានធ្វើដំណើរទៅប៉េកាំង ដើម្បីយាងសម្តេចនរោត្តម សីហនុ មកភ្នំពេញ។ ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៩១ សម្តេចនរោត្តម សីហនុ ដែលអមដំណើរដោយលោក ហ៊ុន សែន ក្រោមការពាររបស់កងកម្លាំង Miprenuc បានមកដល់កម្ពុជា ។ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៩១ គណប្រតិភូកម្ពុជាប្រជាធិបតេយ្យមួយដឹកនាំដោយលោក សុន សេន មកភ្នំពេញ។ ថ្ងៃទី២២ ខែវិច្ឆិកាកិច្ចប្រជុំទី១ របស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ នៅក្រុងភ្នំពេញ ប៉ុន្តែគ្មានវត្តមានរបស់លោក សឺន សាន និង ខៀវ សំផន ទេ ។ ថ្ងៃទី២៧ ខែវិច្ឆិកាឆ្នាំ១៩៩១ លោក ខៀវ សំផន និង លោក សុន សេន បានធ្វើដំណើរចូលមកទីក្រុងភ្នំពេញ ដើម្បីបំពេញមុខងារជាសមាជិកក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ប៉ុន្តែពេលមកដល់ភ្នំពេញ ត្រូវបានស្វាគមន៍ដោយបាតុកម្មមួយក្រុមរបស់ប្រជាជននៅភ្នំពេញ ។ លោក ខៀវ សំផន ត្រូវក្រុមបាតុករវាយឱ្យរបួស ក្រោយមកដោយសារមានអន្តរាគមន៍របស់លោក ហ៊ុន សែន និងកងទ័ពរដ្ឋកម្ពុជា លោកសុន សេន និង លោក ខៀវ សំផន បានរួចផុតពីគ្រោះថ្នាក់ត្រឡប់ទៅបាងកកវិញ។ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៩១មេដឹកនាំខ្មែរក្រហមប្រជុំគ្នានៅជិតប៉ៃលិន ដើម្បីវាយតម្លៃការអនុវត្តកិច្ចព្រមព្រៀងសម្ព័ន្ធភាព។ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩១ មានការប្រជុំការងារយោធាលើកទី១ ដោយមានតំណាងកងទ័ព ៤ ភាគីចូលរួម ហើយបានយល់ស្របគ្នាលើការឈប់បាញ់ និងជានាលើការហោះហើរយន្តហោះ និងឧទ្ធម្ភាគចក្ររបស់មីប្រេនុច MIPRENUC (បេសកកម្មត្រៀមរៀបចំរបស់អង្គការសហប្រជាជាតិនៅកម្ពុជា)។ ថ្ងៃទី៣០ ខែធ្នូ ប្រជុំក្រុមប្រឹក្សាជាតិជាន់ខ្ពស់ នៅ

ភ្នំពេញដោយមានតំណាងភាគីទាំង៤ចូលរួម ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ អំពាវនាវឱ្យកម្លាំងរក្សាសន្តិភាពមកកម្ពុជាឱ្យបានឆាប់រហ័ស។

ថ្ងៃទី៨ ខែមករា ឆ្នាំ១៩៩២ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានអនុម័តលើដំណោះស្រាយមួយស្តីពីការប្រតិបត្តិការរបស់ UNAMIC, SNC និងការថែរក្សាបទឈប់បាញ់គ្នា។ ក្រុមប្រឹក្សាក៏សំដែងការព្រួយបារម្ភផងដែរអំពីអត្ថិភាពនៃមីននិងចម្ការមីននៅក្នុងប្រទេសកម្ពុជា និងពិចារណាលើការបង្កើតកម្មវិធីបណ្តុះបណ្តាលក្នុងការបោសសំអាតមីន។ ថ្ងៃទី៩ ខែមករា ឆ្នាំ១៩៩២ លោក យ៉ាស៊ូស៊ីអាកាស៊ី (Yasushi Akashi) ជនជាតិជប៉ុន ត្រូវបានតែងតាំងជាតំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា។

ថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៩២ សម្តេចនរោត្តម សីហនុ សម្តែងការព្រួយបារម្ភចំពោះការរំលោភលើបទឈប់បាញ់នៅកម្ពុជាពីសំណាក់ពួកខ្មែរក្រហម។ ថ្ងៃទី២៥ ខែមករា សម្តេចនរោត្តម សីហនុ បានប្រកាសថា គ្មានកងទ័ពវៀតណាមលើទឹកដីកម្ពុជាទេ។ ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ១៩៩២ ពួកខ្មែរក្រហមបានរួមប្រជុំគ្នានៅប៉ៃលិន ក្នុងគោលបំណងនាំគ្នាប្តេជ្ញាចិត្តមិនព្រមអនុវត្តកិច្ចព្រមព្រៀងទីក្រុងប៉ារីស។ លោក ខៀវ សំផន ថ្លែងការណ៍សម្តែងការព្រួយបារម្ភអំពីការសម្រេចទិសដៅសំខាន់ៗនៃសន្ធិសញ្ញាប៉ារីសដូចជា ៖

-គ្មានការត្រួតពិនិត្យការដកកងកម្លាំងវៀតណាមចេញពីកម្ពុជា។

-ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ មិនមានតួនាទីអ្វីទាំងអស់ដែលខុសពីការចែងនៅក្នុងសន្ធិសញ្ញាប៉ារីស ដែលកំណត់ថាក្រុមប្រឹក្សាជាតិជាន់ខ្ពស់ជាអង្គការស្របច្បាប់តែមួយគត់ និងជាប្រភពអំណាចតែមួយគត់នៅកម្ពុជា។

-ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ មិនមានតួនាទីចូលរៀបចំឱ្យមានបរិយាកាសនយោបាយអព្យាក្រឹតដើម្បីរៀបចំការបោះឆ្នោត ជាដើម។

ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៩២ ឧត្តមសេនីយ៍ ឡូរីដុង សម្ដែងកំហឹងក្រេវក្រោធរបស់ខ្លួន នៅពេលចូលក្នុងតំបន់របស់ខ្លួន និង មិនឱ្យយន្តហោះ ឬ ឧទ្ធម្ភាគចក្ររបស់ មីប្រេនុច ហោះកាត់តំបន់ខ្មែរក្រហម។

ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៩២ នៅ "ញ៉ូយ៉ក" (New York) ទីស្នាក់ការអង្គការសហប្រជាជាតិ ក្រុមប្រឹក្សា សន្តិសុខ បានអនុម័តផែនការអនុវត្តសេចក្តីសម្រេចរបស់កិច្ចព្រមព្រៀង សន្តិភាពនៅកម្ពុជា ដែលបានយល់ព្រមនៅទីក្រុងបារីស៍។ ផែនការនេះ ការដាក់ពង្រាយកងទ័ពអង្គការសហប្រជាជាតិ មន្ត្រីប៉ូលិសនិងអ្នកគ្រប់ គ្រងស៊ីវិលប្រហែល ២២០០០នាក់ដែលត្រូវកំណត់ក្នុងរយៈពេល១៨ខែ ដោយមានថវិកាភ្ជាប់ជាមួយចំនួន ២.៨០០.០០០.០០០ ដុល្លាអាម៉េរិក។ អាជ្ញាធរបណ្ដោះអាសន្ននៃអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ហៅកាត់ថា អ៊ុនតាក់ (UNTAC) បានបង្កើតឡើងដើម្បីអនុវត្តផែនការ។ ថ្ងៃទី០៦ ខែមីនា អគ្គលេខាធិការអង្គសហប្រជាជាតិ បានតែងតាំងឥស្សរៈជនជាន់ខ្ពស់សំខាន់ៗសម្រាប់ អ៊ុនតាក់ UNTAC។

ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៩២ សម្ដេចនរោត្តម សីហនុ យាងទៅទស្សនកិច្ចនៅប៉ៃលិន ព្រះអង្គថ្លែងថា ត្រូវគោរពសន្ធិសញ្ញាក្រុងប៉ារីស១០០%។ តែលោក សុន សេន គូសបញ្ជាក់ថា បេសកកម្មរបស់ មីប្រេនុច មានកម្រិតត្រូវរង់ចាំដល់អ៊ុនតាក់មកដល់សិន។ ថ្ងៃទី ១១ ខែមីនា កងទ័ពអង្គការសហប្រជាជាតិបានមកដល់ប្រទេសកម្ពុជា ខណៈខ្មែរក្រហមធ្វើការវាយប្រហារមួយដ៏ខ្លាំងក្លានៅកំពង់ធំ។

ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩២ ការចាប់ផ្ដើមដឹកជញ្ជូនជនភៀសខ្លួនកម្ពុជា៦៣០នាក់ ក្នុងចំណោមអ្នករស់ នៅតាមជំរុំនានាក្នុងទឹកដី ថៃដែលមានសរុប ៣៧០ ០០០ នាក់ ឱ្យចូល

មកក្នុងកម្ពុជាវិញ។ ថ្ងៃទី១ ខែមេសា ប្រទេស "អូស្ត្រាលី" (Australie) ព្រមានថានឹងដកកងកម្លាំងយោធារបស់ខ្លួនដែលបំពេញបេសកម្មនៅកម្ពុជា បើការប្រយុទ្ធនៅតែបន្ត ។ ថ្ងៃទី៦ ខែមេសា លោក អាកាស៊ី សុំឱ្យខ្មែរក្រហមបើកតំបន់របស់ខ្លួន ដើម្បីឱ្យអ៊ុនតាក់ចូលត្រួតពិនិត្យ។ ខៀវ សំផន ទាមទារឱ្យត្រួតពិនិត្យការដកកម្លាំងវៀតណាមចេញពីកម្ពុជា និងការប្រមូលផ្តុំកម្លាំងភាគីនីមួយៗនៅមួយកន្លែងជាមុនសិន។

នៅថ្ងៃទី១៨-២១ ខែមេសា ឆ្នាំ១៩៩២ ទស្សនកិច្ចរបស់លោក ប៊ូត្រូសហ្គាលី (Boutros Ghali) អគ្គលេខាធិការអង្គការសហប្រជាជាតិនៅកម្ពុជា។ កិច្ចប្រជុំរបស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ដើម្បីយល់ព្រមទទួលយកអនុសញ្ញាស្តីពីការគោរពសិទ្ធិមនុស្ស។ លោក ខៀវ សំផន បានប្រឆាំងចំពោះប្រាក់ជំនួយ១១លានដុល្លារ សម្រាប់ស្តារបេនាសម្ព័ន្ធរដ្ឋបាលកម្ពុជាឡើងវិញ។

នាថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩២ ក្រុម "រណសិស្សរំដោះពលរដ្ឋខ្មែរ" បើកសន្និបាតរបស់ខ្លួននៅភ្នំពេញហើយបានបង្កើត គណបក្សនយោបាយពេញលក្ខណៈមួយមានឈ្មោះថា គណបក្សសេរីនិយមប្រជាធិបតេយ្យពុទ្ធសាសនា។

ថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩២ លោក អាកាស៊ី ប្រកាសថា មិនឃើញមានភស្តុតាងស្តីពីវត្តមានកងទ័ព វៀតណាមនៅក្នុងប្រទេសកម្ពុជាទេ ប៉ុន្តែថា ការដកកងទ័ពវៀតណាមមុននេះ មិនមានការចូលរួមត្រួតពិនិត្យពីអន្តរជាតិជាផ្លូវការ។ ថ្ងៃទី៣០ ខែឧសភា តំណាងពិសេសរបស់អង្គការសហប្រជាជាតិ លោក អាកាស៊ី និង អគ្គបញ្ជាការកងកម្លាំងរបស់អ៊ុនតាក់ ឧត្តមសេនីយ៍ Sanderson ត្រូវខ្មែរក្រហមរាំងមិនឱ្យចូលទៅក្នុងតំបន់ប៉ៃលិន ហើយប្រកាសថា នឹងមិនអនុវត្តកិច្ចព្រមព្រៀងក្រុងប៉ារីសជារៀងរហូត។

ដើមខែមិថុនា ការចាប់ផ្តើមដំណាក់កាលទី២របស់ UNTAC ដែលត្រូវដកហូតសព្វាវុធពីគ្រប់ភាគី តែខ្មែរក្រហមមិនព្រមអនុញ្ញាតឲ្យ UNTAC ចូលតំបន់ដែលគ្រប់គ្រងដោយ

កម្លាំងរបស់ខ្លួននោះទេ។ ហេតុនេះ អ៊ុនតាក់ មិនបានអនុវត្តន៍ការងារដំណាក់កាលទី១ បានពេញលេញនៅឡើយទេ។

ថ្ងៃទី២២-២៣ខែមិថុនា ឆ្នាំ១៩៩២ សន្និសីទស្តីពីការកសាងប្រទេសកម្ពុជាឡើងវិញ ត្រូវបានធ្វើឡើងនៅទីក្រុងតូក្យូ។ ប្រទេស ៣៣ និងអង្គការអន្តរជាតិចំនួន១៣ បានសន្យានិងផ្តល់ជំនួយប្រមាណ ៨៨០លានដុល្លាអាម៉េរិក សម្រាប់២ឆ្នាំ។

ថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៩៩២ កិច្ចប្រជុំក្រុមប្រឹក្សាជាតិជាន់ខ្ពស់បង្ហាញថា ខ្មែរក្រហមនៅតែមិនព្រមអនុវត្តន៍សន្ធិសញ្ញាក្រុងប៉ារីស។ លោក ហ៊ុន សែន ទាមទារឱ្យដាក់ទណ្ឌកម្មខាងនយោបាយ និងខាងសេដ្ឋកិច្ចលើពួកខ្មែរក្រហម។ នៅខែកក្កដា នេះខ្មែរក្រហមបង្កើនការប្រយុទ្ធបន្ថែមទៀតនៅទូទាំងប្រទេស។ ថ្ងៃទី៤ ខែសីហា អ្នកការទូតចិនម្នាក់បានទៅជួប ប៉ុល ពត ដោយសម្ងាត់ ប៉ុន្តែពួកគេនៅតែមិនព្រមបន្ធន់ឥរិយាបថដដែល។

ថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩២ ប្រជុំក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៅសៀមរាប លោក អាកាស៊ី ផ្សាយច្បាប់បោះឆ្នោត ទោះបីខ្មែរក្រហមប្រឆាំងមិនចូលរួមក៏ដោយ។ ថ្ងៃទី១៣ ខែសីហា អ្នកតំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិសម្រាប់កម្ពុជា បានចុះហត្ថលេខាលើច្បាប់បោះឆ្នោតអ៊ុនតាក់ដែលជាផែន សម្រាប់ការបោះឆ្នោតពហុបក្ស ។ ថ្ងៃទី១៣ ខែសីហា គណបក្សនយោបាយនៅកម្ពុជា ចាប់ផ្តើមចុះឈ្មោះជាបណ្តោះអាសន្នដើម្បីឈរឈ្មោះក្នុងការបោះឆ្នោត។

ថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩២ ប្រទេសថៃ និងប្រទេសជប៉ុន ស្នើអោយបង្កើតរចនាសម្ព័នរដ្ឋបាលមួយ ដែលមានក្រុមប្រឹក្សាជាតិជាន់ខ្ពស់ជាអ្នកគ្រប់គ្រង។ អង្គការអាប្រូនុច ចាប់ផ្តើមពិនិត្យមើលលើសញ្ជាតិ និងដើមកំណើតនៃអ្នករដ្ឋការរបបរដ្ឋកម្ពុជា។ នៅក្រុងបាងកកមានការជួបប្រជុំក្រុម ជប៉ុន ថៃ ជាមួយ ខៀវ សំផន។ មានការកែសម្រួលផ្សេងៗជាមុន" ដើម្បីឱ្យខ្មែរក្រហមមានលទ្ធភាពចូលរួមត្រួតពិនិត្យអាជ្ញាធរផ្សេងៗដែលមាននៅនឹងកន្លែង។

ថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៩២ ជនភៀសខ្លួនខ្មែរប្រមាណ១០ម៉ឺននាក់ ត្រូវបញ្ជូនឲ្យត្រឡប់មកស្រុកខ្មែរវិញ។ ថ្ងៃទី០៤ ខែកញ្ញា ក្នុងកិច្ចប្រជុំនៅទីក្រុង "ហ្សាការតា" (Jakarta) ប្រទេសឥណ្ឌូនេស៊ី រដ្ឋ មន្ត្រីការបរទេសនៃប្រទេស "អាស៊ាន" (ASEAN) ជំទាស់នឹងការបោះ ឆ្នោតនៅកម្ពុជា បើគ្មានការចូលរួមពីខ្មែរក្រហម ។ ថ្ងៃទី៥ ខែតុលា ការចុះឈ្មោះបោះឆ្នោតបានចាប់ផ្តើមនៅរាជធានីភ្នំពេញ និងនៅតាមបណ្តាខេត្តនានាក្នុងរយៈពេលបីខែ ដែលជាចុងក្រោយមានចំនួនអ្នកបោះឆ្នោតចំនួន ៤ ៧៦៤ ៤៣០ នាក់។

នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩២ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ទាមទារឱ្យខ្មែរក្រហមគោរពពេញលេញជាមួយនឹងដំណាក់កាលទី២នៃកិច្ចព្រមព្រៀងប៉ារីស។ ក្រុមប្រឹក្សា ក៏ទាមទារឱ្យភាគីកម្ពុជាទាំងអស់គោរពការឈប់បាញ់គ្នាជួយអ៊ុនតាក់ ដើម្បីកំណត់អត្តសញ្ញាណចម្ការមីនកុំឱ្យពង្រីកចម្ការមីនបន្ថែម និងជួយសម្រួលដល់អ៊ុនតាក់ ក្នុងការស៊ើបអង្កេតរបាយការណ៍កងកម្លាំងបរទេសនៅកម្ពុជា។ ថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៩២ ខ្មែរក្រហមទាត់ចោលគ្រប់សំណើររបស់ជប៉ុន និងថៃទាក់ទងនឹងការបោះឆ្នោត។ ថ្ងៃទី៧-៨ ខែវិច្ឆិកា ប្រជុំក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៅប៉េកាំង នៅចំពោះមុខសហប្រធានសន្និសីទក្រុងប៉ារីស និងលោក អាកាស៊ី។ ខ្មែរក្រហមរក្សាជំហររបស់ខ្លួនទាក់ ទងនឹងការបោះឆ្នោតដដែល។

ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩២ អគ្គលេខាធិការអង្គការសហប្រជាជាតិ ប្រកាសលក្ខខណ្ឌបញ្ចប់រាល់សកម្មភាពយោធានៃភាគីជម្លោះនៅលើទឹកដីខ្មែរ។ ក្នុងរបាយការណ៍មួយផ្ញើទៅក្រុមប្រឹក្សាសន្តិសុខ អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ បានបញ្ជាក់អំពីការឈប់ដកសព្វាវុធដែលមានកំណត់ក្នុងកិច្ចព្រមព្រៀងទីក្រុងបារីស។ ថ្ងៃទី១៩ ខែវិច្ឆិកា លោក អាកាស៊ីទទួលស្គាល់ថា ការដកអាវុធពីភាគីផ្សេងៗមិនអាចធ្វើបានមុនការបោះឆ្នោត ដូចដែលសន្ធិសញ្ញាក្រុងប៉ារីសបានកំណត់នោះទេ គាត់ប្រកាសថា ការបង្កើត និងការរៀបចំឱ្យមានបរិយាកាសនយោបាយអព្យាក្រឹត ជាលក្ខខណ្ឌចាំបាច់ខានមិនបាន ដើម្បីរៀបចំការបោះ

ឆ្នោតដោយសេរី និងត្រឹមត្រូវគាត់សង្កេតឃើញថា គ្មានបរិយាកាសនយោបាយអព្យាក្រឹតទេ សមាជិកគណបក្សនយោបាយផ្សេងៗត្រូវទទួលការគំរាមកំហែងគ្រប់បែបយ៉ាង។ គណបក្សផ្សេងៗមិនអាចធ្វើសកម្មភាពនយោបាយដោយសេរីទេ។

ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩២ ពួកខ្មែរក្រហមបង្កើតគណបក្សរួបរួមជាតិកម្ពុជា (CNUP: Cambodian National Unity Party) ដឹកនាំដោយ ខៀវ សំផន ដើម្បីចូល រួមក្នុងការបោះឆ្នោតសកលឆ្នាំ១៩៩៣ ដែលរៀបចំដោយអាជ្ញាធរបណ្តោះអាសន្ន អង្គការសហប្រជាជាតិនៅកម្ពុជា(អ៊ុនតាក់)។ ប៉ុន្តែគណបក្សនេះបានធ្វើពហិការមិនចូលរួមការបោះឆ្នោតនេះទេ។ ក្រុមប្រឹក្សាសន្តិសុខបានថ្កោលទោសឥរិយាបថខ្មែរក្រហម ហើយបាន ដាក់ទណ្ឌកម្មពាណិជ្ជកម្មជាពិសេសប្រេងដើម្បីលក់ដោះដូរ ក្នុងតំបន់ខ្មែរក្រហម ហើយបញ្ជាឱ្យថៃបញ្ឈប់ការអនុញ្ញាតឱ្យនាំចេញតាមរយៈឈើនិងត្បូងដែលជាប្រភពចំណូលសំខាន់បំផុតរបស់ខ្មែរក្រហម។ ថ្ងៃទី២៨ ខែធ្នូ លោក ខៀវ សំផន មេដឹកនាំខ្មែរក្រហមបានព្រមានថាបុគ្គលិកអង្គការសហប្រជាជាតិ នឹងត្រូវចាប់ខ្លួនប្រសិនបើពួកគេព្យាយាមដាក់ទណ្ឌកម្ម លើពួកខ្មែរក្រហមដោយក្រុមប្រឹក្សាសន្តិសុខ អង្គការសហប្រជាជាតិនេះ។

ថ្ងៃទី០៤ ខែមករា ឆ្នាំ១៩៩៣សម្តេចនរោត្តម សីហនុ បញ្ចប់សហប្រតិបត្តិការរវាងក្រុមប្រឹក្សាជាន់ខ្ពស់ នឹងអង្គការUNTAC ព្រមទាំងរបបរដ្ឋកម្ពុជាផងដែរ ដោយសារសមាជិកគណបក្សហ្វុនស៊ីនប៉ិច១៤នាក់ត្រូវបានគេលបធ្វើឃាត។ មានការកើនឡើងនូវអំពើហិង្សានយោបាយ និងការគំរាមគំហែងសមាជិកគណបក្សមួយចំនួន ដែល អ៊ុនតាក់ មិនអាចគ្រប់គ្រងបាន ។ ហេតុនេះ សម្តេច សីហនុ ជាប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់បានជូនដំណឹងដល់អ៊ុនតាក់ក្នុងលិខិតថា គាត់នឹងដកខ្លួនចេញពីដំណើរការសន្តិភាពនៅកម្ពុជា។ ថ្ងៃទី៨ ខែមករា ក្រោយជំនួបជាមួយលោក អាកាស៊ី ប្រធាន UNTAC សម្តេចនរោត្តម សីហនុ ក៏ដូរព្រះទ័យត្រឡប់មកធ្វើទំនាក់ទំនងនឹង UNTAC វិញ ។

ថ្ងៃទី១១ ខែមករា ឆ្នាំ១៩៩៣ អ៊ុនតាក់ បានប្រកាសការបង្កើតការិយាល័យព្រះរាជអាជ្ញាពិសេសមួយដើម្បីកាត់ទោសអ្នកដែលមានកំហុសខាងនយោបាយ។ ការិយាល័យនេះមានមកពីចម្រុះគណបក្ស ហើយមន្ត្រីប៉ូលីសអាចប្រតិបត្តិការបានក្រោមការឧបត្ថម្ភ និងកាគាំទ្ររបស់អ៊ុនតាក់។ ថ្ងៃទី២៦ ខែមករាខ្មែរក្រហមចេញសេចក្តីថ្លែងការណ៍មួយនៅភ្នំពេញថា នឹងមិនចូលរួមក្នុងដំណើរការសន្តិភាពទេ លុះត្រាតែមានការផ្តល់ចំណែកនៃអំណាច និងធានាថាជនជាតិវៀតណាមទាំងអស់បានចាកចេញពីកម្ពុជា។ ថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៣ ថ្ងៃចុងក្រោយនៃការចុះឈ្មោះសម្រាប់ការរៀបបោះឆ្នោត របស់គណបក្សនយោបាយ ជិតផុតកំណត់ តែខ្មែរក្រហមមិនទាន់មកចុះឈ្មោះទេ។ តែក្រុមប្រឹក្សាជាតិជាន់ខ្ពស់ជាតិនៃកម្ពុជា និងអ្នកតំណាងអ៊ុនតាក់បានប្រកាសថា ការបោះឆ្នោតទូទៅមួយសម្រាប់រដ្ឋសភាដែលមាន១២០ អាសនៈ នឹងត្រូវធ្វើនៅថ្ងៃទី២៣-២៤ខែឧសភា ឆ្នាំ១៩៩៣។ ថ្ងៃទី៣១ ខែមករា បញ្ជីចុះឈ្មោះគណបក្សនយោបាយត្រូវបានបិទបញ្ចប់។ បញ្ជីអ្នកបោះឆ្នោតក៏ត្រូវបានបិទបញ្ចប់ដែរ។ ចំនួនអ្នកបោះឆ្នោតមានទាំងអស់ ៤.៧៦៤.៤៣០នាក់ ។

ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៩៣ លោក Gerard Porcell បានប្រកាសលាលែងពីដំណែងដោយលើកឡើងអំពីការបរាជ័យរបស់អង្គការសហប្រជាជាតិ ក្នុងការដែលមិនអាចលុបបំបាត់នូវអំពើហឹង្សា និងការគំរាមកំហែងដែលប្រព្រឹត្តឡើងដោយក្រុមខ្មែរក្រហម និងភាគីផ្សេងៗទៀត។

ថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៩៣ ក្រុមប្រឹក្សាសន្តិសុខ អ.ស.ប. បានផ្តល់ការយល់ព្រមលើការរៀបចំការបោះឆ្នោតនៅកម្ពុជា ។ ថ្ងៃទី៣ ខែមេសា ក្នុងកិច្ចសម្ភាសន៍ជាមួយ Far Eastern Economic Review លោកខៀវ សំផន បានប្រមាថចោលនូវការបោះឆ្នោតដែលនឹងធ្វើឡើងនាពេលខាងមុខ ដោយចោទថា ជាផែនការរបស់ពួកលោកខាងលិច ដើម្បីបំផ្លាញ

ពួកខ្មែរក្រហម និងបានធ្វើការអំពាវនាវឱ្យបង្កើតនូវរដ្ឋាភិបាលថ្នាក់ជាតិមួយដោយរួមបញ្ចូលទាំងសមាជិកខ្មែរក្រហម ដោយមិនចាំបាច់មានការបោះឆ្នោតអ្វីឡើយ។

ថ្ងៃទី០៧ ខែមេសា ឆ្នាំ១៩៩៣ យុទ្ធនាការឃោសនាបោះឆ្នោតបានចាប់ផ្តើម ។ លោក ប៊ូទ្រូស ប៊ូទ្រូស ហ្គាលី (Boutros Boutros Ghali) អគ្គលេខាធិការនៃ អ.ស.ប. បានអញ្ជើញមកកម្ពុជា ដើម្បីពិនិត្យមើលស្ថានភាពនៃការឃោសនារបស់គណបក្សនយោបាយនានា។ ថ្ងៃទី ០៨ ខែមេសា លោក Atsuhito Nakata អ្នកសង្កេតការណ៍បោះឆ្នោតរបស់អង្គការសហប្រជាជាតិ និងអ្នកបកប្រែរបស់គាត់ត្រូវបានបាញ់សម្លាប់។ ចាប់ពីពេលនោះមក អ្នកស្ម័គ្រចិត្ត ៤០ នាក់នៃអង្គការសហប្រជាជាតិបានលាលែងពីតំណែង។

ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៩៣ សម្តេចនរោត្តម សីហនុ យាងត្រឡប់ទៅប៉េកាំងប្រទេសចិន ។ ថ្ងៃទី១៣ ខែមេសា ពួកមេដឹកនាំខ្មែរក្រហម បានចាកចេញពីក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជានៅទីក្រុងភ្នំពេញ និងវិលត្រឡប់ទៅកាន់មូលដ្ឋានតស៊ូវិញ ដោយមិនបានចូលរួមការបោះឆ្នោតដែលរៀបចំឡើងដោយអ៊ុនតាក់។ ថ្ងៃទី៤ ខែឧសភា ខ្មែរក្រហមវាយប្រហារទៅលើអង្គភាពយោធាចិន នៃកម្លាំងអន្តរាគមន៍ UNTAC នៅកំពង់ធំ។ ថ្ងៃទី១៤ ខែឧសភា ក្រុមគ្រួសារបុគ្គលិក UNTAC ទទួលបទបញ្ជាត្រូវចាកចេញពីកម្ពុជា។ នៅប៉េកាំង សម្តេចនរោត្តមសីហនុ បានធ្វើការរិះគន់UNTACដែលកំពុងរៀបចំការបោះឆ្នោតនៅកម្ពុជា។

ថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៩៣ សម្តេចនរោត្តម សីហនុ យាងត្រឡប់មកភ្នំពេញវិញ។ ថ្ងៃទី២៣ ឧសភា ការបោះឆ្នោតជាសកលដែលរៀបចំឡើងដោយ UNTACនៅកម្ពុជា បានចាប់ផ្តើម និងប្រើរយៈពេល៥ថ្ងៃ គឺដល់ថ្ងៃទី២៨ ខែឧសភា ដែលមានការិយាល័យបោះឆ្នោតអចល័តចំនួន១៤០០ និងការិយាល័យចល័តចំនួន២០០ទៀត សម្រាប់ចល័តទៅដល់ប្រជាពលរដ្ឋ អ្នកបោះឆ្នោតនៅតាមតំបន់ដាច់ស្រយាល។ ថ្ងៃទី២៨ ខែឧសភា ប្រជាពលរដ្ឋបានចូលរួមបោះឆ្នោតចំនួន ៨៩.៥៦% នៃចំនួនអ្នកចុះឈ្មោះសរុប។ គណបក្សប្រជាជនកម្ពុ

ជា (CPP) បានជំទាស់ជាផ្លូវការចំពោះចំណាត់ការមួយចំនួនរបស់ UNTAC ក្នុងការរៀបចំការបោះឆ្នោត ដែលបង្ហាញអំពីភាពមិនយុត្តិធម៌។ ថ្ងៃ២៩ ខែឧសភា លោក អាកាស៊ី ប្រមុខអ៊ុនតាក់ ចេញសេចក្តីថ្លែងការណ៍ជាផ្លូវការផ្ញើជូនអេសអិនស៊ី SNC ប្រកាសថា ការបោះឆ្នោតត្រូវបានប្រព្រឹត្តឡើងដោយសេរីនិងយុត្តិធម៌។ ថ្ងៃទី២ ខែមិថុនា ក្រុមប្រឹក្សាសន្តិសុខ អ.ស.ប បានអនុម័តយល់ព្រមតាមសេចក្តីថ្លែង ការណ៍របស់លោក អាកាស៊ី ថាការបោះឆ្នោតមានលក្ខណៈអន្តរជាតិយ៉ាងពេញលេញ ក្នុងខណៈពេលដែលគណបក្សប្រជាជនកម្ពុជានៅបន្តការតវ៉ានៅឡើយ។

ថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៩៩៣ សម្តេចនរោត្តម សីហនុ ចាប់ផ្តើមប្រឆាំងនឹង UNTAC ហើយស្នើបង្កើតរដ្ឋាភិបាលចម្រុះមួយរវាងគណបក្សប្រជាជនកម្ពុជា និងហ៊្វុនស៊ិនប៉ិច។ សម្តេចនរោត្តម សីហនុ ប្រកាសតែងតាំងខ្លួនព្រះអង្គជានាយករដ្ឋមន្ត្រី និងជាអគ្គបញ្ជាការកងទ័ពខ្មែរ ដោយជ្រើសរើសព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ និងលោក ហ៊ុន សែន ជាឧបនាយករដ្ឋមន្ត្រី ប៉ុន្តែព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ ដែលជាប្រធានគណបក្សហ្វុនស៊ិនប៉ិច បានបញ្ចេញអារម្មណ៍ស្ទាក់ស្ទើរក្នុងការគាំទ្រ ។ ថ្ងៃទី៤ ខែមិថុនា ប្រទេសបារាំងគាំទ្រសំណើររបស់សម្តេចនរោត្តម សីហនុ ក្នុងការបង្កើតរដ្ឋាភិបាលចម្រុះ។ ប៉ុន្តែមិនមានការយល់ស្របពីសំណាក់UNTAC។

ថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៣ នៅពេលលោក Akashi ប្រមុខអ៊ុនតាក់ធ្វើការប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការក្នុងសម័យប្រជុំ អេសអិនស៊ី ថា ការបោះឆ្នោតបានប្រព្រឹត្តទៅដោយសេរី និង យុត្តិធម៌។ ហ៊្វុនស៊ិនប៉ិចទទួលបាន ១.៨២ លានសម្លេងឬ ៤៥.៥ ភាគរយ ។ CPP មាន ១.៥៣ លានសម្លេងឬ ៣៨.២ភាគរយ ។ BLDP ១៥២ ៧៦៤ សម្លេងឬ ៣.៨ភាគរយ ដែលក្នុងនោះគណបក្សហ៊្វុនស៊ិនប៉ិចទទួលបាន ៥៨ អាសនៈ។ CPP ៥១ BLDP ១០ អាសនៈនិង ម៉ូលីណាកា (Moulinaka) ១ អាសនៈ។ ភាគីគណបក្សហ្វុនស៊ីនប៉ិច

និងភាគីគណបក្សប្រជាធិបតេយ្យនិយមព្រះពុទ្ធសាសនា បានទទួលយកនូវលទ្ធផលបោះឆ្នោតនេះភ្លាមៗ ប៉ុន្តែគណបក្សប្រជាជនកម្ពុជានៅមានមន្ទិល បានប្រកាសអំពី«ភាពមិនប្រក្រតីជាច្រើន» នៃលទ្ធផលការបោះឆ្នោត។ ព្រះអង្គម្ចាស់នរោត្តមចក្រពង្ស ព្រះរាជបុត្រព្រះនរោត្តមសីហនុ រួមជាមួយថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជាមួយចំនួន ប្រកាសធ្វើអប្បគម បំបែកយកខេត្ត៦ នៅត្រើយខាងកើតទន្លេមេគង្គ ។ ថ្ងៃទី១១ ខែមិថុនា អ៊ុន តាក់ UNTAC បានប្រកាសជាផ្លូវការនូវលទ្ធផលបោះឆ្នោត និងបញ្ជីតំណាងរាស្ត្រទាំង១២០រូប។ ខ្មែរក្រហមប្រកាសទទួលស្គាល់លទ្ធផលបោះឆ្នោត។ ក្នុងខណៈពេលដែលគណបក្សប្រជាជនកម្ពុជា ស្នើឱ្យមានការពិនិត្យឡើងវិញលើបញ្ហាមួយចំនួន។

## ៣.៣.ការសម្របសម្រួលក្រោយការបោះឆ្នោត

ថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៩៣ ព្រះអង្គម្ចាស់នរោត្តមចក្រពង្ស បានប្រកាសបង្កើតតំបន់ស្វយ័តក្នុងខេត្តកំពង់ចាម ព្រៃវែង និងស្វាយរៀង បន្ទាប់ពីមានការប្រកាសលទ្ធផលបោះឆ្នោត។ ព្រះអង្គម្ចាស់ទាមទារឱ្យគណបក្សហ្វុនស៊ិនប៉ិច បង្កើតរដ្ឋាភិបាលចម្រុះជាមួយគណបក្សប្រជាជនកម្ពុជា។ ថ្ងៃទី១៤ ខែមិថុនា គណបក្សប្រជាជនកម្ពុជា បានទទួលយកផែនការរបស់សម្តេចនរោត្តម សីហនុ ដែលនាំទៅរកការបើកផ្លូវឲ្យរដ្ឋសភាធម្មនុញ្ញបើកសម័យប្រជុំ លើកទី១នៃសភាធម្មនុញ្ញដែលបានចាប់ផ្តើមការងាររបស់ខ្លួន ហើយបានពិភាក្សាលើគោលការណ៍សំខាន់ៗ ដែលចែងក្នុងរដ្ឋធម្មនុញ្ញ អំពីរបបនយោបាយ ដែលត្រូវយកមកអនុវត្តន៍នៅកម្ពុជា។ សភាធម្មនុញ្ញអនុម័តសេចក្តីសម្រេចប្រកាសទុកជាមោឃៈចំពោះការបោះឆ្នោតទម្លាក់ សម្តេចនរោត្តម សីហនុ ពីតួនាទីព្រះប្រមុខរដ្ឋកម្ពុជានាថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ហើយបានផ្តល់អំណាចគ្រប់បែបយ៉ាងថ្វាយព្រះអង្គវិញគិតចាប់ពីឆ្នាំ១៩៧០តរៀងមកដោយគ្មានលួសថ្ងៃខែឆ្នាំណាឡើយ។ សម្តេចនរោត្តម សីហនុ ប្រកាស់

រំលាយរដ្ឋាភិបាលជាតិរបស់ព្រះអង្គ។ គណបក្សហ៊្វុនស៊ីនប៉ិច និងគណបក្សប្រជាជន យល់ព្រមចែករំលែកអំណាចក្នុងរដ្ឋាភិបាលបណ្ដោះអាសន្នមួយ។ កិច្ចព្រមព្រៀងនេះយល់ព្រមឱ្យព្រះអង្គម្ចាស់រណឫទ្ធិ និងលោកហ៊ុនសែនធ្វើជាសហនាយករដ្ឋមន្ត្រី។ គណបក្សតូចៗពីរ គឺគណបក្សប្រជាធិបតេយ្យសេរី និង មូលីណាកា ក៏ត្រូវបានចូលរួមនៅក្នុងរដ្ឋាភិបាលបណ្ដោះអាសន្ន រហូតទាល់តែសភាធម្មនុញ្ញបានព្រាងរដ្ឋធម្មនុញ្ញថ្មីមួយ។ ព្រះអង្គម្ចាស់រណឫទ្ធិ និងសម្ដេចហ៊ុនសែនយល់ស្របថា សម្ដេច សីហនុ នឹងធ្វើជាមេបញ្ជាការជាន់ខ្ពស់បណ្ដោះអាសន្ននៃកងកម្លាំងប្រដាប់អាវុធកម្ពុជា ។ ថ្ងៃទី២០ ខែមិថុនា គណបក្សប្រជាជនកម្ពុជាទទួលស្គាល់លទ្ធផលការបោះឆ្នោត។

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៣ សភាធម្មនុញ្ញ បានអោយសច្ចាប័នទៅលើសមាសភាពនៃរដ្ឋាភិបាល។ លោក ស៊ឹន សាន ដែលមានអាយុច្រើនជាងគេ ត្រូវបានជ្រើសរើសធ្វើជាប្រធានសភាធម្មនុញ្ញ ។ ថ្ងៃទី១ ខែកក្កដា សភាធម្មនុញ្ញ បោះឆ្នោតផ្ដល់សេចក្ដីទុកចិត្តជូនរដ្ឋាភិបាលចម្រុះ បណ្ដោះអាសន្ន ។ ថ្ងៃទី២ ខែកក្កដា សម្ដេចនរោត្តម សីហនុ ប្រមុខរដ្ឋនៃកម្ពុជា បានតែងតាំងរដ្ឋាភិបាលជាតិបណ្ដោះអាសន្ននៃកម្ពុជា។ រដ្ឋាភិបាលជាតិបណ្ដោះអាសន្ននេះមានសមាសភាពជាសហប្រធានគឺ ព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ និងឯកឧត្តម ហ៊ុន សែន។

ថ្ងៃទី៣ ខែកក្កដា ឆ្នាំ១៩៩៣ លោកប្រមុខរដ្ឋចិន ហ្យ៉ាំង យ៉េមីញ និង លោកមន្ត្រីទី១ ចិន លីប៉ឹង បានផ្ញើលិខិតសសើរសម្ដេចនរោត្តម សីហនុ យ៉ាងជ្រាលជ្រៅពីការបង្កើតរដ្ឋាភិបាលចម្រុះ។ ថ្ងៃទី៥-៦ ខែកក្កដា រដ្ឋមន្ត្រីក្រសួងការពារជាតិប្រទេសបារាំង "លោកហ្វ្រង់ស្វ័រឡេអូតា" (François Léotard) ធ្វើទស្សនកិច្ចនៅកម្ពុជា។ ក្នុងឱកាសនោះកិច្ចសហប្រតិបត្តិការយោធារវាងប្រទេសទាំងពីរត្រូវបានចុះហត្ថលេខា ។ លោកស្រី ម៉ាដឺឡែន អ៊ុលប្រាយ ឯកអគ្គរដ្ឋទូតសហរដ្ឋអាម៉េរិកប្រចាំអង្គការសហប្រជាជាតិបានធ្វើទស្សនកិច្ចនៅ

កម្ពុជា ។ សហរដ្ឋអាម៉េរិកមានគោលជំហប្រឆាំងខ្មែរក្រហមក្នុងរដ្ឋាភិបាលកម្ពុជាថ្មី។ ថ្ងៃទី៨ ខែកក្កដា ក្រុមទាំងបីមានគណបក្សប្រជាជនកម្ពុជា ហ៊្វុនស៊ិនប៉ិច និងរណសិរ្សរំដោះជាតិខ្មែរ បានសហប្រតិបត្តិការយោធាទប់ទល់ និងការវាយប្រហាររបស់ខ្មែរក្រហម។

ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៩៣ សម្តេចនរោត្តម សីហនុ អនុញ្ញាតឱ្យលោក ខៀវ សំផន និងអ្នកអមជាមួយលោក រួមមាន លោក ចាន់ យូរ៉ាន់, លោក ម៉ក់ បេន និង លោក អ៊ិន សូភាព ចូលគាល់ព្រះអង្គ។ មានការកំណត់ថា នឹងមានការប្រជុំនៅខែវិច្ឆិកា ដើម្បីបន្តពិភាក្សាការងារនយោបាយដែលនៅសេសសល់។ ពេលនោះ លោក ខៀវ សំផន យកសារមួយរបស់ ប៉ុល ពត ស្នើឱ្យបញ្ចូលកងទ័ពខ្មែរក្រហម ក្នុងទ័ព៤ភាគី ហើយចាត់តាំងទីប្រឹក្សារបស់កម្ពុជាប្រជាធិបតេយ្យ ក្នុងរដ្ឋាភិបាលជាតិបណ្តោះអាសន្ន។

ថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៩៣ ក្រុមប្រឹក្សាសន្តិសុខសហប្រជាជាតិ បានសម្រេចបន្តអាណត្តិអន្តរាគមន៍ របស់ខ្លួននៅកម្ពុជា ដើម្បីដោះស្រាយការងារនយោបាយរវាងគណបក្សរាជានិយមហ្វុនស៊ិនប៉ិច និង គណបក្សប្រជាជន ។

ថ្ងៃទី៨-៩ ខែកញ្ញា ឆ្នាំ១៩៩៣ កិច្ចប្រជុំដំបូងនៅទីក្រុងបារីស៍របស់គណៈកម្មាធិការអន្តរជាតិ ដើម្បី កសាងកម្ពុជាឡើងវិញ (Comité International pour la Reconstruction du cambodge /CIRC/ICORC) ដែលមានប្រទេសចូលរួមប្រមាណ ៣១ និងអង្គការអន្តរជាតិ ១១។ កិច្ចប្រជុំនេះបានសម្រេចផ្តល់ជំនួយ ១១៩ លានដុល្លាអាម៉េរិក បន្ថែមទៅលើជំនួយមុន ៨៨០លានដុល្លារ ដែលបានអនុម័តនៅក្នុងកិច្ចប្រជុំទីក្រុងតូក្យូ ។

ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ រដ្ឋធម្មនុញ្ញថ្មីនៃប្រទេសកម្ពុជាត្រូវបានប្រកាសឱ្យប្រើជាសាធារណៈ និងជាផ្លូវការ ។ សម្តេចនរោត្តម សីហនុ ត្រូវបានអភិសេកជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា រដ្ឋាភិបាលចម្រុះគណបក្សប្រជាជនកម្ពុជា និងហ៊្វុនស៊ិនប៉ិច

បានចាប់ ផ្តើមអាណត្តិដោយមានព្រះអង្គម្ចាស់រណឫទ្ធិ ជានាយករដ្ឋមន្ត្រីទី ១ និងឯកឧត្តម ហ៊ុន សែន ជានាយករដ្ឋមន្ត្រីទី២។

ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៩៣ អ៊ុនតាក់ បានបញ្ចប់បេសកកម្មថែរក្សាសន្តិភាពរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា។ បេសកកម្មនេះមានរយៈពេល ១៨ ខែនិងបានចំណាយអស់ប្រមាណ១.៧ ពាន់លានអឺរ៉ូ ។ ថ្ងៃទី១៥ ខែតុលា កងកម្លាំង អ៊ុនតាក់ UNTAC បានដកចេញពីកម្ពុជាជាផ្លូវការ។

សម្គាល់ ៖ ឯកសារនេះដកស្រង់ទាំងស្រុងពីសៀវភៅ រាជបណ្ឌិត្យសភាកម្ពុជា ***<u>កាលប្រវត្តិសាស្ត្រកម្ពុជា</u>*** ឆ្នាំ២០២១, ៦៩៩ទំព័រ។